ʊ̋ ʆʷ î Ǹ ǿ ɵʊ̋ɰɰ ʈɮ̃̀

Ǹ ɿ ʧȐ ʏ Ȅ ʊ̋ ʆʷ ʈ ȓ ɰʊ̋̀ ɿ

# យុទ្ធសាស្ត្រ និង ផែនការ សកម្មភាពជាតិ ស្តីពី

# ប្រភេទរាតត្បាត

ឧសភា ២០១៦



អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

បោះពុម្ពដោយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន

អំណះអំណាង GSSD 2016. National Invasive Species Strategy and Action Plan, Department of Biodiversity, National Council for Sustainable Development/ Ministry of Environment, Phnom Penh, Cambodia.

រៀបចំដោយ នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន សហការជាមួយគម្រោង "ការបំបាត់ភាពរាំងស្ទះ ដល់ការគ្រប់គ្រងប្រភេទទន្ទ្រានរាតត្បាត លើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍_FORIS" ក្រោមជំនួយឧបត្ថម្ភរបស់ GEF/UNEP។

កែសម្រួលដោយ **លោក ម៉េង មុនីរក្ស**

ឧបត្ថម្ភដោយ មូលនិធិបរិស្ថានពិភពលោក (GEF) តាមរយៈកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និង មជ្ឈមណ្ឌលកសិកម្ម និងជីវៈចម្រុះអន្តរជាតិ(CABI)

រចនាដោយ នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

រូបក្របមុខ រូបរុក្ខជាតិ ថតដោយ **លោក សេង រដ្ឋា** រីឯរូបសត្វទាញយកពីអ៊ីនធឺនេត

អាចទាញយកបានពី www.moe.gov.kh
www.chm.gdancp-moe.org
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងបន្តប្តេជ្ញាការពារថែរក្សាធនធានធម្មជាតិ រួមទាំងធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី តាមគ្រប់រូបភាព និងមធ្យោបាយ សំដៅចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាសហគមន៍នៅមូលដ្ឋាន គាំពារវិស័យសំខាន់ៗ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមាននិរន្តរភាព។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ និងអនុសញ្ញាសហប្រជាជាតិមួយចំនួន មានដូចជាអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងអនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងវាលខ្សាច់កម្ម។

ដូចមានចែងនៅក្នុងកម្មវិធីព្រៃឈើជាតិ២០១០-២០២៩ រាជរដ្ឋាភិបាលកម្ពុជា មានផែនការការពារ និងថែរក្សាគម្របព្រៃឈើឱ្យបាន៦០%នៃផ្ទៃដីប្រទេស ព្រមទាំងទប់ស្កាត់ការបាត់បង់ធនធានជីវៈចម្រុះដែលបណ្តាលមកពីកត្តានានា និងសកម្មភាពអភិវឌ្ឍន៍។ ដើម្បីសម្រេចបាននូវមហិច្ឆិតានេះ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងពីគ្រប់ស្ថាប័ន ជំនាញ និងបណ្តាអ្នកពាក់ព័ន្ធនានាដែលមានការពាក់ព័ន្ធជាមួយធនធានជីវៈចម្រុះ គម្របព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី។ ហេតុនេះហើយទើបនាយកដ្ឋានជីវៈចម្រុះនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាសេនាធិការដ្ឋាននៃរាជរដ្ឋាភិបាលកម្ពុជា បានសម្របសម្រួលរៀបចំ "*យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត*" នេះឡើង ដែលយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះ កំណត់វិធានការជាយុទ្ធសាស្ត្រមួយចំនួនក្នុងកិច្ចខិតខំប្រឹងប្រែងសម្រេចឱ្យបាននូវគោលដៅជីវៈចម្រុះជាតិតាមផែនការអភិវឌ្ឍជាតិវិស័យនីមួយៗ។

ប្រភេទរាតត្បាត ទាំងសត្វ រុក្ខជាតិ ឬមីក្រូសរីរាង្គ បាននិងកំពុងបង្កបញ្ហា និងការគំរាមកំហែងសំរាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត។ ពិភពលោកបានចាត់ទុកប្រភេទរាតត្បាត ជាសត្រូវទីពីរធ្ងន់ធ្ងរ បន្ទាប់ពីការកាប់បំផ្លាញព្រៃឈើ និងដែនជំរកនៃធនធានជីវៈចម្រុះនានា។ ការធ្វើជំនួញដូរពាណិជ្ជកម្ម និងការធ្វើដំណើរឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយ ពីតំបន់មួយទៅតំបន់មួយ ជាសក្តានុពល និងឱកាសឱ្យប្រភេទក្រៅស្រុក ឬប្រភេទនាំចូល បង្កហានិភ័យរាតត្បាតនៅក្នុងប្រទេស តាមរយៈភ្នាក់ងារសត្វ រុក្ខជាតិ និងមីក្រូសរីរាង្គ ដែលបានពាំនាំយកមកជាមួយ ហើយសត្វ រុក្ខជាតិ និងសរីរាង្គទាំងនោះ ក៏បានបោះទីតាំងថ្មី និងរីករាលដាលជាបន្តបន្ទាប់ ដែលមិនធ្លាប់មាននៅទីនោះពីមុនមក។ ពិតមែនតែ ប្រភេទរាតត្បាតមួយចំនួន មិនអាចរស់រាន និងបន្តពូជនៅទីតាំងថ្មីក៏ដោយ តែក៏មានប្រភេទរាតត្បាតមួយចំនួន មានលទ្ធភាពអាចបន្តពូជ ព្រមទាំងរីករាលដាលដោយខ្លួនឯង។ ជាក់ស្តែង មានប្រភេទរាតត្បាតមួយចំនួន ដូចជាបន្លាព្រះក្លបយក្ស (mimosa pigra) បានបង្កផលវិបាកដ៏ធ្ងន់ធ្ងរដល់វិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងពេលបច្ចុប្បន្ន។ ទោះជាយ៉ាងណាក្តី ការវាយតម្លៃទៅលើផលវិបាកដែលបង្កឡើងដោយប្រភេទរាតត្បាតទុកជាមុន ថាតើប្រភេទរាតត្បាតណាមួយ នឹងបង្កបញ្ហាក្នុងកំរិតតិច ឬច្រើន បានជួបនូវបញ្ហាប្រឈមជាច្រើន។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន បានរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ ដើម្បីធ្វើជាគោលការណ៍គ្រឹះសម្រាប់បង្កា និងរារាំងទុកជាមុន។ ចំណាត់ការដើម្បីរារាំងទប់ស្កាត់ប្រភេទរាតត្បាត គឺជាយុទ្ធសាស្ត្រ និងយន្តការដ៏មានប្រសិទ្ធភាព និងប្រសិទ្ធផលបំផុត។ ជាមួយគ្នានេះ ការគ្រប់គ្រង និងការត្រួតត្រាលើប្រភេទរាតត្បាត ក៏ជាយុទ្ធសាស្ត្រចាំបាច់មួយដែរ សម្រាប់យកមកអនុវត្ត ក្នុងខណៈ

ពេលណា ដែលប្រភេទរាតត្បាត បានបោះទីតាំង និងមានវត្តមាននៅក្នុងប្រទេសរួចហើយ។ ទៅអនាគតកម្ពុជា ត្រូវតែរឹតបន្តឹងក្នុងការអនុញ្ញាត ឱ្យនាំចូលប្រភេទរាតត្បាតថ្មីៗតាមរយៈផ្លូវចម្លងនានា ដើម្បីជៀសវាងការកើតឡើងនូវប្រភេទរាតត្បាតថ្មីៗបន្ថែមទៀត។ វិធីសាស្ត្រត្រួតត្រា ឬឃុំគ្រង និងឈានទៅលុបបំបាត់ប្រភេទរាតត្បាតណាមួយ ដែលរកឃើញថាបានបង្កផលអវិជ្ជមាន ដល់ជីវៈចម្រុះ សេដ្ឋកិច្ច ឬសង្គម គឺជាជម្រើសចុងក្រោយ ព្រោះវិធីសាស្ត្រនេះ ត្រូវការធនធានមនុស្ស និងហិរញ្ញវត្ថុ ច្រើន ព្រមទាំងត្រូវការពេលវេលាផងដែរ ដើម្បីគាំទ្រ និងដំណើរការសកម្មភាពនៃវិធីសាស្ត្រនេះ។

គោលនយោបាយជាតិអភិវឌ្ឍន៍នានារបស់ប្រទេសកម្ពុជាសម្រាប់វិស័យនីមួយៗ តម្រូវឱ្យអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថានរាល់គម្រោង និងសកម្មភាពអភិវឌ្ឍន៍នានា។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ លើកទឹកចិត្តឱ្យមានការបញ្ជ្រាបចូលទៅក្នុងផែនការអភិវឌ្ឍន៍របស់វិស័យផ្សេងៗ និងមានការបែងចែងពីការទទួលខុសត្រូវទៅតាមវិស័យនិងដែនសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ។

ដំណើរការសំខាន់ៗនៃការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ បានរៀបចំឡើងដោយមានការចូលរួមពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័ន អង្គភាពទទួលខុសត្រូវ និងបណ្តាអ្នកពាក់ព័ន្ធនឹងធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ក្នុងនោះរួមមានសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិចំនួន២លើក និងពិភាក្សាក្នុងអង្គប្រជុំអនុគណៈកម្មាធិការបច្ចេកទេសជាតិគ្រប់គ្រងជីវៈចម្រុះចំនួន២លើក។ រាល់កិច្ចប្រជុំថ្នាក់ជាតិ មានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួងជំនាញ គ្រឹះស្ថានអប់រំ អាជ្ញាធរថ្នាក់ក្រោមជាតិ សង្គមស៊ីវិល និងអ្នកជំនាញការផងដែរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីតំណាងឱ្យក្រសួង ស្ថាប័នជាតិ អង្គភាព គ្រឹះស្ថានអប់រំ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដែលបានសហការល្អ និងផ្តល់ធាតុចូល ព្រមទាំងគំនិត យោបល់ ទស្សនៈ និងជំនាញ ក្នុងការដំណើរការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ ឱ្យលេចចេញជារូបរាងឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

ឯកសារ*យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាគត្បាត* គឺជាសមិទ្ធផលមួយកើតចេញពីកិច្ចសហការរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ឯកសារនេះ ទទួលបានការគាំទ្រយ៉ាងផុលផុសក្នុងការផ្តល់យោបល់កែលម្អ និងធាតុចូលនៅក្នុងដំណើរការរៀបចំតាក់តែង និងពិគ្រោះយោបល់ឆ្លងពីអនុគណៈកម្មាធិការបច្ចេកទេសគ្រប់គ្រងជីវៈចម្រុះសម្រាប់អនុវត្តគម្រោងស្តីពី *"ការបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទទន្រ្ទានរាគត្បាតលើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍* FORIS" ពីស្ថាប័នរដ្ឋពាក់ព័ន្ធមួយចំនួន ពីវិទ្យាស្ថានស្រាវជ្រាវ និងអប់រំ ពីសង្គមស៊ីវិល និងពីដៃគូអភិវឌ្ឍន៍។

នាយកដ្ឋានជីវៈចម្រុះនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងវិសេសវិសាលដល់**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ចំពោះការដឹកនាំដ៏វិសេសវិសាល ការយកចិត្តទុកដាក់ឥតងាករេ និងកិច្ចគាំទ្រយ៉ាងខ្លាំងក្លាទៅលើការងារអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន។ យើង ក៏សូមថ្លែងអំណរគុណ និងកោតសរសើរ **ឯកឧត្តម យិន គិមស៊ាន** រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានអនុគណៈកម្មាធិការបច្ចេកទេសជាតិគ្រប់គ្រងជីវៈចម្រុះនេះ ដែលបានដឹកនាំផ្ទាល់រាល់កិច្ចដំណើរការរៀបចំ ពិគ្រោះយោបល់ និងពិនិត្យឆ្លងឯកសារដ៏មានសារៈសំខាន់នេះ។ សេចក្តីថ្លែងអំណរគុណជាពិសេស និងដ៏ប្រសើរមានចំពោះ**ឯកឧត្តម ឆិន ពន្លក** អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព **ឯកឧត្តម ចាយ សាមិត្ត** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ដែលជាអតីតប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និង**លោកជំទាវ ចាន់ សុម៉ាលី** អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលបានណែនាំ ជួយគាំទ្រ និងជំរុញលើកទឹកចិត្តក្រុមការងាររៀបចំ និងដំណើរការរៀបចំឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះឡើង។

តាងនាមឱ្យក្រុមការងារ និងលេខាធិការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាគត្បាត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោក លោកស្រី ដែលជាសមាជិកអនុគណៈកម្មាធិការបច្ចេកទេសជាតិគ្រប់គ្រងជីវៈចម្រុះ ក្នុងការចូលរួមគាំទ្រ ផ្តល់គំនិតយោបល់ កែលម្អ និងធាតុចូលគ្រប់ដំណាក់កាលរៀបចំឯកសារនេះឡើង និងជាពិសេសចំពោះសមាជិកគណៈកម្មការគ្រប់គ្រងគម្រោង ដែលបានជួយគាំទ្រក្នុងការសម្របសម្រួល កែសម្រួលខ្លឹមសារ រចនាបទ និងបកប្រែ។

សូមសំដែងអំណរគុណដល់តំណាងក្រសួង ស្ថាប័នជាតិពាក់ព័ន្ធ វិទ្យាស្ថានស្រាវជ្រាវ និងអប់រំ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល និងបណ្តាអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមចែករំលែកបទពិសោធន៍ និងបានផ្តល់ព័ត៌មាន ព្រមទាំងយោបល់ក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាគត្បាតនេះ ឱ្យកាន់តែមានសង្គតិភាព មានលក្ខណៈប្រសើរ និងមានភាពងាយស្រួលក្នុងពេលអនុវត្ត។ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងវិស័យសំខាន់ៗ គឺជាគោលការណ៍គ្រឹះនៃការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាគត្បាត។

ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ ទទួលបានការគាំទ្រថវិកាពីគម្រោង "***ការបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទទន្ទ្រានរាតត្បាតលើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍***" តាមរយៈមូលនីធិបរិស្ថានពិភពលោក UNEP ដែលមាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន ជាស្ថាប័នប្រតិបត្តិ និងសម្របសម្រួលបច្ចេកទេស ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីអង្គការ CAB International។ ការរៀបចំឯកសារនេះ ការជំរុញលើកទឹកចិត្តពីលោកបណ្ឌិត **Arne Witt** ទីប្រឹក្សាជាន់ខ្ពស់របស់ CAB International និងដែលបានពិនិត្យកែសម្រួលឯកសារជាភាសាអង់គ្លេស។

ជាទីបញ្ចប់ យើងសូមសំដែងអំណរគុណចំពោះមន្ត្រីនាយកដ្ឋានជីវៈចម្រុះទាំងអស់ និងមន្ត្រីក្នុងក្រសួងបរិស្ថាន ចំពោះការតាំងចិត្ត កិច្ចសហការ កិច្ចសម្របសម្រួល និងភាពមុះមុត ចូលរួមរៀបចំ ផ្តល់គំនិតយោបល់ស្ថាបនា កែសម្រួល និងពិនិត្យឆ្លងឯកសាររាល់ដំណាក់កាលរៀបចំ ដែលបានធ្វើឱ្យឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត អាចរៀបចំបោះពុម្ពតាមផែនការ និងផ្សព្វផ្សាយអនុវត្តបន្ត។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៦

**ម៉េង មុនីរក្ស**
ប្រធានគម្រោង និងជា
ប្រធាននាយកដ្ឋានជីវៈចម្រុះ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

# អនុគណៈកម្មាធិការបច្ចេកទេសជាតិគ្រប់គ្រងជីវៈចម្រុះ

## សម្រាប់អនុវត្តគម្រោងស្តីពី " ការបំបាត់ភាពរាំងស្ទះ ដល់ការគ្រប់គ្រងប្រភេទទន្ទ្រានរាត ត្បាត លើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍_FORIS"

| | | |
|---|---|---|
| ឯកឧត្តម **យិន គិមស៊ាន** | រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន | ប្រធាន |
| ឯកឧត្តម **ជា សំអាង** | អនុប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| លោក **ម៉ូ ចន្ទសិរី** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| លោក **ម៉េង មុនីរក្ស** | ប្រធាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជាប្រធាន គម្រោង FORIS ថ្នាក់ជាតិ | សមាជិក |
| លោក **វណ្ណា សំណាង** | អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| លោក **ពេជ ចន្ទ័** | អនុប្រធាននាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនង សាធារណៈ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| លោក **ថាច់ សុវណ្ណា** | និងអភិរក្សធនធានទឹក អនុប្រធាននាយកដ្ឋានគ្រប់គ្រង នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| លោក **ស្រ៊ន់ ពិធូ** | ប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងអនុ សាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |

# គណៈកម្មការគ្រប់គ្រងគម្រោង

## "ការបំបាត់ភាពរាំងស្ទះ ដល់ការគ្រប់គ្រងប្រភេទទន្សាយរាតត្បាត លើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍_FORIS"

| | | |
|---|---|---|
| លោកជំទាវ **ចាន់ សុម៉ាលី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | ប្រធាន |
| លោក **ម៉េង មុនីរក្ស** | ប្រធាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជាប្រធានគម្រោង FORIS ថ្នាក់ជាតិ | អនុប្រធាន |
| លោក **សេង រដ្ឋធា** | អ្នកសម្របសម្រួលគម្រោង FORIS ថ្នាក់ជាតិ | សមាជិក |
| លោកស្រី **គី លីណែត** | មន្ត្រីគម្រោងផ្នែកគណនេយ្យ និងលទ្ធកម្ម | សមាជិក |
| លោកស្រី **ត្លួង សុធី** | មន្ត្រីគម្រោងផ្នែករដ្ឋបាល | សមាជិក |

# មាតិកា


**អារម្ភកថា** ........ i

**សេចក្តីថ្លែងអំណរគុណ** ........ iii

**មាតិកា** ........ vii

**វាក្យស័ព្ទសំខាន់ៗ** ........ ix

**សេចក្តីសង្ខេប** ........ xi

**១. សេចក្តីផ្តើម** ........ 1

១.១. មូលហេតុ និងភាពប្រឈម ........ 1

១.២. វិសាលភាព ........ 3

**២. ចក្ខុវិស័យ** ........ 3

**៣. បេសកកម្ម** ........ 3

**៤. គោលបំណង** ........ 3

**៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........ 3

៥.១. គោលការណ៍គ្រឹះសម្រាប់គ្រប់គ្រងប្រភេទរាតត្បាត ........ 3

៥.២. ទិសដៅជាយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយផលប៉ះពាល់របស់ប្រភេទរាតត្បាតទៅលើជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ........ 4

៥.២.១. វិធានការណ៍សម្រាប់រារាំង ឬបង្ការ ........ 4

៥.២.២. វិធានការណ៍សម្រាប់ផ្តល់សញ្ញាបន្ទាន់ និងឆ្លើយតបភ្លាមៗ ........ 5

៥.២.៣ វិធានការណ៍សម្រាប់ត្រួតត្រា និងគ្រប់គ្រង ........ 6

៥.២.៤. វិធានការណ៍សម្រាប់ស្តារឡើងវិញ ........ 7

**៦. ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិក្នុងក្របខ័ណ្ឌគោលនយោបាយ** ........ 7

**៦.១. ការកសាងសមត្ថភាពសម្រាប់រារាំង និងគ្រប់គ្រងប្រភេទរាតត្បាត** ........ 7

៦.១.១. ការកសាងធនធានមនុស្ស ........ 7

៦.១.២. ការពង្រឹងក្របខ័ណ្ឌស្ថាប័ន និងកិច្ចសហការណ៍រវាងស្ថាប័ន ........ 8

**៦.២. ឧបករណ៍ និងយុទ្ធសាស្ត្រ** ........ 8

៦.២.១. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់រារាំង ........ 8

៦.២.២. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់ផ្តល់សញ្ញាបន្ទាន់ និងឆ្លើយតបភ្លាមៗ ........ 9

៦.២.៣. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់ត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត ........ 10

៦.២.៤. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់ស្តារឡើងវិញ ........ 11

**៦.៣. ការគាំទ្រលើការគ្រប់គ្រងព័ត៌មាន និងការផ្សព្វផ្សាយ** ........ 11

៦.៣.១ គោលការណ៍ណែនាំ ........ 11

៦.៣.២. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង ........ 12

**៦.៤. ការចូលរួមរបស់សាធារណជនក្នុងការរារាំង និងការគ្រប់គ្រងប្រភេទរាតត្បាត** ........ 12

៦.៤.១. គោលការណ៍ណែនាំ ........ 13

៦.៤.២. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង 13
**៦.៥. ការរៀបចំគោលនយោបាយសេដ្ឋកិច្ច** 14
**៦.៦. ការពិនិត្យ និងការតាក់តែងលិខិតបទដ្ឋានច្បាប់សមស្រប** 14
៦.៦.១. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង 15
**៦.៧. ការពង្រឹងកិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ និងជាមួយប្រទេសក្នុងតំបន់** 15
៦.៧.១. គោលការណ៍ណែនាំ 15
៦.៧.២. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង 16
**៧. ក្របខ័ណ្ឌស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត** 16
**៧.១. ស្ថាប័នជាតិ** 17
**៧.២. អាជ្ញាធរថែនដី** 17
**៧.៣. សហគមន៍មូលដ្ឋាន** 17
**៧.៤. សង្គមស៊ីវិល** 18
**៧.៥. វិស័យឯកជន** 18
**៨. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់** 19
**៨.១. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ** 19
៨.១.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 19
៨.១.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម 19
៨.១.៣. យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ 19
៨.១.៤. យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ 19
**៨.២. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងគោលនយោបាយជាតិ** 20
**៨.៣. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងក្របខ័ណ្ឌច្បាប់** 20
**៩. ប្រភពធនធានហិរញ្ញវត្ថុ** 20
**៩.១. រដ្ឋាភិបាល** 20
**៩.២. ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ** 21
**៩.៣. វិស័យឯកជន** 21
**១០. ការតាមដាន និងការវាយតម្លៃ** 21

**សន្និដ្ឋាន និងអនុសាសន៍** 23
**ឧបសម្ព័ន្ធ** 25
ឧបសម្ព័ន្ធ១៖ សកម្មភាពអាទិភាពសម្រាប់គ្រប់គ្រងប្រភេទរាតត្បាត 25
ឧបសម្ព័ន្ធ២៖ និតិវិធីជាគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការណ៍របស់ស្ថានប័នពាក់ព័ន្ធនានា 27
ឧបសម្ព័ន្ធ៣៖ ក្របខ័ណ្ឌគោលនយោបាយ និងការគ្រប់គ្រងប្រភេទរាតត្បាត 28
ឧបសម្ព័ន្ធ៤៖ បញ្ជីឈ្មោះនៃប្រភេទរាតត្បាតអាទិភាពនៅកម្ពុជាដែលត្រូវមានវិធានការកំចាត់ 28

# វាក្យស័ព្ទសំខាន់ៗ

**ការឃ្លាំមើល** )surveillance(៖ ការសិក្សាស្រាវជ្រាវទៅលើទំហំរាលដាលនៃបញ្ហារបស់ប្រភេទណាមួយ ហើយបន្ទាប់មករៀបចំជាលក្ខណៈវិនិច្ឆ័យសម្រាប់តាមដាន។

**ការតាមដាន** (monitoring)៖ ការសង្កេតតាមដានជាប្រចាំទៅលើភាពពុះកញ្ជ្រោល និងទំហំសាយភាយនៃបញ្ហារបស់ប្រភេទរាតត្បាត និងទៅលើជម្រើសនានាដែលបានយកមកគ្រប់គ្រង។

**ការត្រួតត្រា** (control)៖ ជាការគ្រប់គ្រងជម្ងឺ ឬប្រភេទណាមួយឱ្យវាស្ថិតនៅក្នុងកម្រិតកំណត់មួយ ដែលអាចទទួលយកបាន (ឧទាហរណ៍ កម្រិតដង់ស៊ីតេ កម្រិតរបាយរាយប៉ាយ ឬកម្រិតគ្រោះថ្នាក់)។

**ការត្រួតត្រាចម្រុះ** (integrational control)៖ ការគ្រប់គ្រងនៃជម្ងឺ ឬប្រភេទណាមួយដោយការប្រើបញ្ចូលគ្នានៃជម្រើសផ្សេងៗ ដើម្បីទាញផលប្រយោជន៍ល្អក្នុងគោលបំណងនៃការគ្រប់គ្រង។

**ការផ្តល់សញ្ញាបន្ទាន់** (early warning)៖ ជាការដាស់តឿនរំលឹកអំពីការមកដល់ ឬការឃើញមានវត្តមាន និងការជួបបញ្ហារបស់ប្រភេទក្រៅស្រុកណាមួយ មុនពេលបញ្ហានោះបានក្លាយជាបញ្ហាចាក់ឫសគល់។

**ការនាំចូលដោយចេតនា** (intentional introduction)៖ ការនាំចូលរបស់មនុស្សដោយមានបំណងអ្វីមួយ គឺមានការពាក់ព័ន្ធទៅនឹងការធ្វើចលនា ឬចរាចរក្នុងគោលដៅជាក់លាក់នៃប្រភេទក្រៅស្រុកណាមួយចេញពីដែនធម្មជាតិរបស់វា ហើយប្រភេទក្រៅស្រុកនោះ មានសក្តានុពលពង្រាយបន្តទៅតំបន់ ឬទៅកន្លែងផ្សេងៗ។ សកម្មភាពនាំចូលបែបនេះ អាចចាត់ទុកថាជាអំពើស្របច្បាប់ ឬខុសច្បាប់។

**ការនាំចូលដោយអចេតនា** (unintentional introduction)៖ ការនាំចូលដោយអចេតនាកើតចេញពីផលនៃការប្រើប្រាស់របស់មនុស្ស ឬក៏ប្រព័ន្ធសកម្មភាពចែកចាយរបស់មនុស្ស ដែលមានមុខងារជាភ្នាក់ងារចម្លងនៃការពង្រីកភាពរាយប៉ាយទៅខាងក្រៅតំបន់ធម្មជាតិរបស់ប្រភេទក្រៅស្រុកនោះ។

**ការប្រើភ្នាក់ងារសរីរាង្គរស់ត្រួតពិនិត្យជីវសាស្ត្រ** (bio-control)៖ គឺជាវិធានការណ៍ដែលមានប្រសិទ្ធភាព និងមានលក្ខណៈបរិស្ថានជាមូលដ្ឋាន សម្រាប់កាត់បន្ថយឥទ្ធិពលរបស់ប្រភេទរាតត្បាតតាមរយៈការប្រើសត្រូវធម្មជាតិរបស់ប្រភេទរាតត្បាត។

**ការរាតត្បាត** (invasion)៖ ការរីករាលដាលនៃប្រភេទមួយទៅក្នុងទីតាំង ឬទីកន្លែងថ្មីណាមួយ ជាទូទៅវាមានឥទ្ធិពលបំផ្លាញទៅលើប្រភេទដើមកំណើត សកម្មភាពអភិវឌ្ឍន៍ និងជាទូទៅ ប៉ះពាល់ទៅលើសុខភាពរបស់មនុស្ស។ ***សំគាល់*** ៖ មានករណីជាច្រើន បានបង្ហាញពីផលវិបាកកើតចេញពីប្រភេទក្រៅស្រុកតាមរយៈផ្លូវចម្លង **ប្រភេទក្រៅស្រុកបានបន្សាំខ្លួនជាមួយនឹងបរិស្ថានថ្មី** ហើយបន្ទាប់មកវាបានក្លាយជា **ការរាតត្បាត**។ ជាទូទៅ ការរាតត្បាត អាចកើតមានក្នុងរយៈពេលខ្លី តែមិនមែនគ្រប់ប្រភេទក្រៅស្រុកទាំងអស់នោះទេ និងគ្រប់ស្ថានការណ៍ឡើយ។

**ការវាយតម្លៃហានិភ័យ** (risk assessment)៖ ជាដំណើរការវាយតម្លៃទៅលើហានិភ័យនៃការនាំចូលប្រភេទក្រៅស្រុកដែលអាចក្លាយជាប្រភេទរាតត្បាត ឬដែលអាចបង្កជាបញ្ហានានាទៅថ្ងៃក្រោយ។

**ជីវៈចម្រុះ** (biodiversity or biological diversity)៖ ជាភាពនានានៃសរីរាង្គដែលមានជីវិតនៅគ្រប់ធនធានធម្មជាតិ រួមទាំងប្រព័ន្ធអេកូឡូស៊ីដីគោក សមុទ្រ និង វារីជាតិ និងភាពសាំញ៉ាំនៃប្រព័ន្ធអេកូឡូស៊ី ដែលក្នុង

នោះពួកគេ គឺជាផ្នែកមួយប៉ុណ្ណោះ។ ជីវៈចម្រុះ គិតរួមទាំងភាពសម្បូរក្នុងប្រភេទតែមួយ ឬរវាងប្រភេទមួយទៅមួយ និងភាពសម្បូរនៃប្រព័ន្ធអេកូឡូស៊ី។

**ប្រភេទក្នុងស្រុក** (indigenous species)៖ ជាប្រភេទដែលមានកំណើតដើមក្នុងតំបន់ណាមួយនៃប្រទេសកម្ពុជា មិនមែនជាប្រភេទដែលបាននាំចូលដោយសារកត្តាអ្វីមួយ។

**ប្រភេទក្រៅស្រុក** (alien or exotic species)៖ ជាប្រភេទដែលបាននាំចូលពីខាងក្រៅទៅក្នុងទីតាំង ទីជម្រក ឬដែនធម្មជាតិខុសពីដីកំណើតរបស់វា ឬជាប្រភេទណាមួយដែលមិនមែនជាប្រភេទក្នុងស្រុក ឬប្រភេទមានដើមកំណើតនៃប្រព័ន្ធអេកូឡូស៊ីជាក់លាក់ណាមួយក្នុងតំបន់។

**ប្រភេទរាតត្បាត ឬប្រភេទទន្ទ្រានរាតត្បាត** (invasive alien species)៖ គឺជាប្រភេទរាតត្បាតនៃប្រភេទក្រៅស្រុកឬប្រភេទមិនមានដើមកំណើតក្នុងធម្មជាតិនៃប្រព័ន្ធអេកូឡូស៊ីក្នុងប្រទេសកម្ពុជា ឬក្នុងតំបន់។

**ប្រព័ន្ធអេកូឡូស៊ី** (ecosystem)៖ ជាកន្លែង ទីជម្រក ដែនជម្រក ទីតាំងណាមួយនៃធម្មជាតិដែលបានបង្កើតឡើងដោយសារអន្តរអំពើរបស់សរីរាង្គដែលមានប្រតិកម្មរវាងគ្នាទៅវិញទៅមក ទៅនឹងបរិស្ថានជុំវិញរបស់គេ ឧទាហរណ៍ ព្រៃឈើ ដីសើម បឹង ត្រពាំង ទន្លេ ភ្នំ ដីស្រែចំការ ទីក្រុង ទីប្រជុំជន។

**ផ្លូវចម្លង** (pathway)៖ ជាមធ្យោបាយ ឬជាផ្លូវដែលប្រភេទក្រៅស្រុកបានធ្វើដំណើរពីកន្លែងដើមកំណើត ឬពីទីតាំងថ្មីទៅកាន់កន្លែងមួយទៀតដែលប្រភេទក្រៅស្រុកនោះ មិនធ្លាប់មានពីមុនមក។

**ភូតគាមអនាម័យ** (quarantine)៖ ការដាក់ឱ្យនៅដាច់ដោយឡែកនៃសរីរាង្គក្នុងគោលបំណងរារាំងការឆ្លងជម្ងឺ ឬការបង្កាគ្រោះថ្នាក់ទៅលើសរីរាង្គដទៃទៀត។ សេវាភូតគាមអនាម័យ គឺសំដៅទៅរកដំណើរការពិនិត្យ ឆែកឆេរបឋមទៅលើសរីរាង្គដែលកំពុងនាំចូល ដើម្បីពិនិត្យរកមើលសក្តានុពលហានិភ័យរបស់ប្រភេទនាំចូលដែលបង្កឱ្យខូចខាត និងបន្ទាប់មកចាត់វិធានការរារាំងដល់ការកើតមានគ្រោះថ្នាក់ទាំងនោះ។

**រុក្ខជាតិចង្រៃ** (weed)៖ ជារុក្ខជាតិបានដុះនៅកន្លែងណាមួយ ដែលគេមិនត្រូវការ ឬជារុក្ខជាតិមិនមានតម្លៃសេដ្ឋកិច្ច ដែលបានដុះនៅក្នុងព្រៃ និងត្រូវបានគេចាត់ទុកថាជារុក្ខជាតិរំខានដល់ការដុះលូតលាស់របស់ប្រភេទដទៃទៀត (ជាទូទៅមិនទាន់រកឃើញមានតម្លៃឬផលប្រយោជន៍)។

# សេចក្តីសង្ខេប

ដោយមានការយល់ដឹងកាន់តែខ្លាំងឡើងៗពីហានិភ័យនៃវត្តមានប្រភេទរាតត្បាត ចំពោះបរិស្ថាន សេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា ហើយវិស័យចម្បងៗទ្រទ្រង់សេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមរបស់កម្ពុជា អាស្រ័យទៅនឹងធនធានជីវៈចម្រុះ និងសេវាប្រព័ន្ធអេកូឡូស៊ី គួបផ្សំទៅនឹងសកម្មភាពពាណិជ្ជកម្ម វិស័យទេសចរណ៍ និងការដឹកជញ្ជូនឆ្លងកាត់ ទើបក្រសួងបរិស្ថាន ចាំបាច់ត្រូវរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះឡើង ក្នុងគោលបំណងបំពេញភាពខ្វះចន្លោះលើការអនុវត្តកិច្ចខិតខំប្រឹងប្រែង និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃប្រភេទរាតត្បាតនៅចំពោះមុខ និងទៅអនាគតនៃវិស័យបរិស្ថាន កសិកម្ម សកម្មភាពអភិវឌ្ឍន៍នានា និងការប្រែប្រួលអាកាសធាតុ។ ផ្លូវចម្លងឥតដែនកំណត់នៃប្រភេទរាតត្បាតតាមរយៈសកម្មភាពមនុស្សដោយចេតនា និងអចេតនា ក៏ជាបុព្វហេតុចំបង រួមជាមួយនឹងកិច្ចការពារធនធានជីវៈចម្រុះរបស់ប្រទេសកម្ពុជា ទើបតម្រូវឱ្យមានយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះឡើង។

ផ្អែកលើសេចក្តីណែនាំអំពីទម្រង់នៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិរបស់គណៈរដ្ឋមន្ត្រី យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ ត្រូវបានរៀបចំតាក់តែងដោយ៖ **ក**) មានចែងពីមូលហេតុនាំឱ្យកើតមានប្រភេទរាតត្បាតនៅក្នុងប្រទេសកម្ពុជា ហេតុផល និងភាពចាំបាច់ឈានដល់ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះឡើង **ខ**) ការបង្កើតចក្ខុវិស័យ បេសសកម្ម និងគោលបំណងរបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះ **គ**) ការតាក់តែងក្របខ័ណ្ឌយុទ្ធសាស្ត្រទប់ស្កាត់រួម គោលការណ៍គ្រឹះសម្រាប់គ្រប់គ្រង និងទិសដៅយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយ **ឃ**) ការកំណត់កន្សោមសកម្មភាពអនុវត្តនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិក្នុងក្របខ័ណ្ឌគោលនយោបាយ ដែលត្រូវបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់នានា **ង**) តួនាទីរបស់ស្ថាប័នថ្នាក់ជាតិ-ក្រោមជាតិ សង្គមស៊ីវិល និងវិស័យឯកជនជាដើម **ច**) ប្រភពថវិកាគាំទ្រ និង **ឆ**) ការកំណត់ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ។

កំណើនផលទុនជាតិសរុបរបស់កម្ពុជាក្នុងរង្វង់ ៧% ទៅ៨ %ក្នុងរយៈពេលជាងដប់ឆ្នាំកន្លងទៅនេះ មានមូលដ្ឋានអាស្រ័យនឹងសសរស្តម្ភរបស់វិស័យចំនួនបួន គឺកសិកម្ម វាយនភ័ណ្ឌកាត់ដេរ សេវាទេសចរណ៍ និងសំណង់។ កសិកម្ម ជាវិស័យមួយដែលសេដ្ឋកិច្ចកម្ពុជានៅតែខ្វះមិនបាន។ វិស័យកសិកម្មបានរួមចំណែកសេដ្ឋកិច្ចកម្ពុជាក្នុងរង្វង់មិនតិចជាង៣០%នៃផលទុនជាតិសរុបប្រចាំឆ្នាំ។ រាជរដ្ឋាភិបាល បានដាក់ផែនការនាំអង្ករចេញទៅបរទេសចំនួនមួយលានតោនប្រចាំឆ្នាំគិតត្រឹមឆ្នាំ២០១៥។ ក្រៅពីនេះ កម្រិតស្ថេរភាពនៃសេដ្ឋកិច្ចមូលដ្ឋាន និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ប្រែប្រួលទៅតាមកម្រិតអន្តរាគមន៍ និងសុខភាពនៃធនធានជីវៈចម្រុះ និងសេវាមុខងារប្រព័ន្ធអេកូឡូស៊ី ជាពិសេសប្រភេទក្នុងស្រុក។ ប្រភេទរាតត្បាត អាចនឹងធ្វើឱ្យប៉ះពាល់ដល់ភាពសម្បូរបែបនៃធនធានជីវៈចម្រុះ និងសេវាមុខងារប្រព័ន្ធអេកូឡូស៊ី តាមរយៈការប្រកួតប្រជែងដណ្តើមទីជម្រក និងចំណីអាហារ។ ប្រទេសជាច្រើនលើពិភពលោក បានរកឃើញថាវត្តមានប្រភេទរាតត្បាតបានធ្វើឱ្យខូចខាតដល់សេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងទឹកប្រាក់រាប់សិបលានដុល្លាអាមេរិកប្រចាំឆ្នាំ។

បច្ចុប្បន្នអ្នកវិទ្យាសាស្ត្របានរួមសហការជាមួយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានអប់រំ និងសង្គមស៊ីវិល បាននិងកំពុងរិះរកវិធានការណ៍ និងវិធីសាស្ត្រនានាដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីគ្រប់គ្រង ត្រួតត្រា និងកំចាត់ប្រភេទរាតត្បាតដែលកំពុងមានវត្តមាននៅលើពិភពលោក។ ជាអកុសល រាល់វិធានការណ៍ ឬវិធីសាស្ត្រណាមួយដើម្បីគ្រប់គ្រង ត្រួតត្រា និងកំចាត់ប្រភេទរាតត្បាត ចាំបាច់ត្រូវមានថវិកា និងធនធានផ្សេងៗ ជាពិសេសវិធីសាស្ត្រគ្រប់គ្រង ត្រួតត្រា និងកំចាត់ប្រភេទរាតត្បាត តាមរយៈកម្លាំង ឬរូបសាស្ត្រ និងគីមីសាស្ត្រ។ វិធីសាស្ត្រគីមី

មិនទាន់ធានាបាននូវសុវត្ថិភាពបរិស្ថាន និងត្រូវចំណាយអស់ថវិកាច្រើន គឺស្មើគ្នានឹងវិធីសាស្ត្រប្រើកម្លាំង និងមិនមាននិរន្តរភាពឡើយ។

ចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីប្រភេទរាតត្បាតនេះ រៀបចំឡើងដោយផ្អែកលើការវិភាគពីស្ថានភាព ការយល់ដឹង សមត្ថភាព និងលទ្ធភាពរំពឹងទុករបស់កម្ពុជាក្នុងការគ្រប់គ្រងប្រភេទរាតត្បាតនាពេលបច្ចុប្បន្ន និងទៅអនាគត។

**ចក្ខុវិស័យ៖** ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជា នឹងមានភាពប្រសើរឡើង តាមរយៈការគ្រប់គ្រងប្រភេទរាតត្បាតប្រកបដោយប្រសិទ្ធភាពត្រឹមឆ្នាំ២០២៥។

**បេសកកម្ម៖** ក្របខ័ណ្ឌគោលនយោបាយ និងយន្តការគ្រប់គ្រងប្រភេទរាតត្បាតនានា ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ត្រូវបានបង្កើតឡើងសំដៅកាត់បន្ថយហានីភ័យទៅលើធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅត្រឹមឆ្នាំ២០២៥។

**គោលបំណង៖**

- កំណត់វិធានការណ៍សមស្របសម្រាប់រារាំង ទប់ស្កាត់ លុបបំបាត់ ត្រួតត្រា តាមដាន និងគ្រប់គ្រងប្រភេទរាតត្បាត
- បង្កើនការយល់ដឹងពីប្រភេទរាតត្បាត ដែលជាបញ្ហាចំបងបង្កផលប៉ះពាល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា
- ពង្រឹងកិច្ចសហការណ៍ កិច្ចសហប្រតិបត្តិការណ៍ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រងប្រភេទរាតត្បាត។

ដើម្បីសម្រេចចក្ខុវិស័យ បេសសកម្ម និងគោលបំណងរបស់ខ្លួន យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីប្រភេទរាតត្បាត បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

- ត្រូវរារាំង បង្កា ឬទប់ស្កាត់ទៅលើសកម្មភាពនាំឱ្យកើតមានប្រភេទរាតត្បាត និងការនាំចូលប្រភេទក្រៅស្រុក នៅមុនពេលប្រភេទក្រៅស្រុកទាំងនោះ មានវត្តមាន ឬបានចូលមកកាន់ទីតាំងថ្មីបង្កការរាតត្បាត
- ផ្តល់សញ្ញាបន្ទាន់ និងការធ្វើអន្តរាគមន៍ឆ្លើយតបភ្លាមៗ រួមទាំងការលុបបំបាត់ទាំងស្រុង បើសិនជាអាចធ្វើបាន
- ត្រូវត្រួតត្រា និងគ្រប់គ្រងនៃប្រភេទរាតត្បាតក្នុងក្របខ័ណ្ឌមិនឱ្យរាលដាលបន្តទៅទីតាំងថ្មី
- ស្តារឡើងវិញទីតាំង តំបន់ ដែនជម្រក ឬដីប្រើប្រាស់នានា ដែលទទួលរងការគំរាមកំហែង ឬការរិចរិលដោយសារប្រភេទរាតត្បាត។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្រទាំងបួនខាងលើ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីប្រភេទរាតត្បាត ក៏បានដាក់ចេញជាសំណើផែនការសកម្មភាពក្នុងក្របខ័ណ្ឌជាយុទ្ធសាស្ត្រមួយចំនួន រួមមាន៖

- ការកសាងសមត្ថភាពសម្រាប់រារាំង និងគ្រប់គ្រងប្រភេទរាតត្បាត
- ការលើកទឹកចិត្ត និងការគាំទ្រលើការអនុវត្តបែបវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមស្រប
- ការគាំទ្រលើការគ្រប់គ្រងព័ត៌មាន និងការផ្សព្វផ្សាយ
- ចូលរួមរបស់សាធារណជនក្នុងសកម្មភាពរារាំង និងគ្រប់គ្រងប្រភេទរាតត្បាត

- ការរៀបចំគោលនយោបាយសេដ្ឋកិច្ច
- ការពិនិត្យ និងការតាក់តែងលិខិតបទដ្ឋានច្បាប់សមស្រប
- ការពង្រឹងកិច្ចសហការណ៍អន្តរជាតិ និងក្នុងតំបន់។

ភាពចាំបាច់នៃធនធានថវិកាគ្រប់គ្រាន់ និងការចូលរួមពីបណ្តាអ្នកពាក់ព័ន្ធគ្រប់កម្រិត និងពីគ្រប់រចនាសម្ព័ន្ធចាត់តាំងសម្រាប់អនុវត្តសកម្មភាព និងការតាមដានវាយតម្លៃរបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះ ក៏មានចែងនៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះដែរ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះក៏បានគិតគូរដល់និរន្តរភាពនៃសកម្មភាពកំចាត់ គ្រប់គ្រង និងត្រួតត្រាប្រភេទរាតត្បាត ដែលតម្រូវឱ្យបញ្ជ្រាប និងបញ្ចូលទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ និងផែនការអភិវឌ្ឍន៍នានារបស់វិស័យផ្សេងៗ។

# ១. សេចក្តីផ្តើម

## ១.១. មូលហេតុ និងភាពប្រឈម

ការនាំចូលរាល់ប្រភេទក្រៅស្រុក បាននិងកំពុងរីករាលដាលជាមួយនឹងសកម្មភាពពាណិជ្ជកម្ម វិស័យទេសចរណ៍ និងការដឹកជញ្ជូនឆ្លងកាត់។ សកម្មភាពពាណិជ្ជកម្មអន្តរជាតិ ការនាំចូលប្រភេទក្រៅស្រុកដោយចេតនាផង និងអចេតនាផង ដែលអាចបង្កផលប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរ និងមានពេលខ្លះ គេមិនអាចស្តារធម្មជាតិឱ្យមកដូចស្ថានភាពដើមវិញបានឡើយនៅទីតាំងដែលធ្លាប់មានវត្តមានប្រភេទរាតត្បាត។ វិធីផ្សេងៗដែលអាចធ្វើឱ្យកើតមាន ឬធ្វើការនាំចូលប្រភេទរាតត្បាតនេះ គេហៅថា *ផ្លូវចម្លង*។ ផ្លូវចម្លងសំខាន់ៗ អាចជាការធ្វើជំនួញនៃប្រភេទរុក្ខជាតិ ឬសត្វក្រៅស្រុកក្នុងគោលបំណងតាំងលម្អគេហដ្ឋាន គ្រឹះស្ថាន បំរើសួន កសិដ្ឋាន ឬបង្កើនទិន្នផលវិស័យកសិកម្ម បសុសត្វ មច្ឆាជាតិ វារីវប្បកម្ម និងព្រៃឈើ ហើយក្រោយមកប្រភេទរុក្ខជាតិឬសត្វក្រៅស្រុកទាំងនោះបានក្លាយជាប្រភេទរាតត្បាត។ គេក៏អាចរកឃើញប្រភេទរាតត្បាតទាំងនោះមាននៅក្នុងទំនិញ និងសម្ភារៈវេចខ្ចប់ និងតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ ដែលបានដឹកទំនិញទាំងនោះ ហៅថា*វិចទ័រចំលង*។ សកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ព្រៃឈើ វារីវប្បកម្ម និងបសុសត្វ ក៏អាចជាប្រភពចំលងនៃប្រភេទរាតត្បាតដ៏សំខាន់ផងដែរ។

ប្រភេទក្រៅស្រុកដែលបាននាំចូល អាចរីករាលដាលពីទីតាំងមួយទៅទីតាំងមួយ ពីកន្លែងមួយទៅកន្លែងមួយ ពីតំបន់មួយទៅតំបន់នៅទូទាំងប្រទេស និងអាចឆ្លងទៅប្រទេសផ្សេងៗតាមរយៈមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ផ្ទៃប្រទេសតាមផ្លូវគោក ឬផ្លូវទឹក ឬសម្ភារៈវេចខ្ចប់នានា។ កង្វល់ជាពិសេស កើតមានតាមការដឹកជញ្ជូនទៅកាន់តំបន់ដាច់ស្រយាល។ មានភស្តុតាងជាច្រើន បានបង្ហាញពីការរាលដាលនៃប្រភេទរាតត្បាតទៅដល់តំបន់ដាច់ស្រយាលដល់ទីប្រជុំជន និងដល់តំបន់ទីវាលនានា ជាពិសេសនៅតាមដងផ្លូវសាធារណៈ។ ប្រភេទរាតត្បាតរស់ក្នុងទឹក បានដុះនិងរស់ក្នុងទីតាំងថ្មីតាមរយៈទូកកប៉ាល់នាវា ឬចរន្តទឹកហូរចុះឡើង។ គេមានការលំបាកជាខ្លាំងក្នុងការតាមដាន និងត្រួតត្រាប្រភេទរាតត្បាតទាំងនោះ ដោយសារផ្លូវចម្លងមិនមានដែនកំណត់នៅក្នុងប្រទេស ក៏ដូចជារវាងប្រទេសមួយទៅប្រទេសមួយទៀត។ គេអាចប៉ាន់ស្មានថា ផលប៉ះពាល់ដោយផ្ទាល់របស់ប្រភេទរាតត្បាត ទៅលើសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ គិតជាទឹកប្រាក់ អាចមានតម្លៃរាប់លានដុល្លាអាមេរិក។ ផលប៉ះពាល់ទាំងនេះ គិតបញ្ចូលតែការបាត់បង់ទៅលើផលិតភាព ការចំណាយលើការសំអាតប្រភេទរាតត្បាត និងការខាតបង់ប្រាក់ចំណូលពីវិស័យកសិកម្ម ព្រៃឈើ ជលផល និងពាណិជ្ជកម្ម តែមិនបានគិតបញ្ចូលពីការខូចខាតនៃមុខងារ និងសេវាប្រព័ន្ធអេកូឡូស៊ី ព្រមទាំងសុខភាពមនុស្សនិង សត្វឡើយ។

យោងតាមឯកសារ *គម្រោងការបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទរាតត្បាតលើកិច្ចការពារ អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍* ដែលសិក្សាទៅលើភាពពាក់ព័ន្ធនៃគោលនយោបាយ នីតិប្បញ្ញត្តិ មុខងារភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័ន ទីភ្នាក់ងារ ឬអង្គភាពសម្រាប់គ្រប់គ្រង និងដោះស្រាយបញ្ហាប្រភេទរាតត្បាត។ គេសង្កេតឃើញនៅមានភាពខ្វះខាតនៃយន្តការនាពេលបច្ចុប្បន្ន គោលការណ៍គ្រឹះ និងគោលការណ៍ណែនាំដែលបានកម្រិតដែនកំណត់លើសកម្មភាពពាក់ព័ន្ធមួយចំនួន ដូចជាកិច្ចការរារាំង ការទប់ស្កាត់ ការផ្តល់សញ្ញាបន្ទាន់ ការឆ្លើយតបភ្លាមៗ ការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត។ ភាពមានកម្រិតកំណត់ទៅលើសកម្មភាពទាំងនោះ បណ្តាលមកពីបញ្ហាប្រឈមចំបងៗចំពោះមុខ រួមមាន៖

ក) កង្វះខាតភាពជាក់លាក់នៃគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព គោលការណ៍ណែនាំ និងនីតិបទដ្ឋានច្បាប់សម្រាប់ដោះស្រាយបញ្ហារាតត្បាត និងគ្រប់គ្រងប្រភេទរាតត្បាត

ខ) ចំណេះដឹងរបស់ស្ថាប័ន ទីភ្នាក់ងារ និងអង្គភាពដែលមានតួនាទី ភារកិច្ច និងសមត្ថកិច្ច ទៅលើបញ្ហាប្រភេទរាតត្បាត មិនទាន់គ្រប់គ្រាន់ និងនៅមានដែនកំណត់

គ) ភាពមិនស៊ីសង្វាក់គ្នានៃស្ថាប័ន និងអង្គភាពផ្សេងៗទៅលើកិច្ចសហការ និងកិច្ចសហប្រតិបត្តិការក្នុងការកំចាត់ប្រភេទរាតត្បាត

ឃ) មិនមានការសិក្សាស្រាវជ្រាវឱ្យបានគ្រប់គ្រាន់ទៅលើប្រភេទរាតត្បាតអាទិភាព និងវិស័យពាក់ព័ន្ធ

ង) កង្វះខាតលើការតាមដាន និងប្រព័ន្ធផ្តល់សញ្ញាភ្លាមៗសម្រាប់ឆ្លើយតបទៅនឹងការរាតត្បាត

ច) កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារ ព្រមទាំងសមត្ថភាពប្រតិបត្តិកូតតាមអនាម័យ

ឆ) មិនមានចំណេះដឹងមូលដ្ឋានគ្រប់គ្រាន់ដែលចាំបាច់សម្រាប់ដោះស្រាយបញ្ហាប្រភេទរាតត្បាត

ជ) ខ្វះខាតប្រព័ន្ធទិន្នន័យព័ត៌មានអំពីចំណេះដឹង និងការប្រើប្រាស់ទាំងក្នុងប្រទេស តំបន់ និងអន្តរជាតិ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន ប្រទេសកម្ពុជាចាំបាច់ត្រូវរៀបចំបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិពេញលេញមួយសម្រាប់សម្រួលដល់ការរារាំង ការផ្តល់សញ្ញាបន្ទាន់ ការឆ្លើយតបភ្លាមៗ ការលុបបំបាត់ ការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត។ លើសពីនេះ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ត្រូវតែយកមកប្រតិបត្តិប្រកបដោយប្រសិទ្ធភាព ផ្អែកលើយុទ្ធសាស្ត្រចំនួនបីខាងក្រោម ដើម្បីឆ្លើយតបទៅនឹងភាពប្រឈម និងដោះស្រាយនៅទូទាំងប្រទេស។ **<u>ទី១៖</u>** *យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះ <u>ត្រូវតែបញ្ជ្រាបបញ្ហាបរិស្ថានទៅគ្រប់សេចក្តីសម្រេចនានា</u> <u>បន្ថែមទៅនឹងកត្តាសេដ្ឋកិច្ចសង្គម</u>*។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ កន្លងមក បានផ្តោតទៅលើការរារាំងទប់ស្កាត់ ឬការបង្កាលើការនាំចូលដោយអចេតនា ចំពោះតែជម្ងឺរាតត្បាតទៅលើវិស័យកសិកម្ម និងជលផលប៉ុណ្ណោះ។ សក្តានុពលនៃវិស័យឯទៀតដែលទទួលរងផលប៉ះពាល់ មិនត្រូវបានពិចារណាជិតដល់នៅក្នុងពេលធ្វើសេចក្តីសម្រេច។ ការកើនឡើងនៃប្រភេទក្រៅស្រុកនានា តាមរយៈការធ្វើពាណិជ្ជកម្ម បានធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ដែនជម្រក និងប្រភេទក្នុងស្រុកដែលកំពុងទទួលរងការគំរាមកំហែងគួរឱ្យព្រួយបារម្ភ។ បច្ចុប្បន្នការពិចារណាអំពីបញ្ហាបរិស្ថាន គ្រាន់តែជាផ្នែកតូចមួយនៃដំណើរការវិភាគលើហានីភ័យ ដែលបណ្តាលមកពីប្រភេទក្រៅស្រុកទទួលបានការអនុញ្ញាតនាំចូល។ ផលវិបាកដែលបណ្តាលមកពីសកម្មភាពនាំចូលប្រភេទក្រៅស្រុក ពេលខ្លះមានទំហំធំធេង និងមិនអាចវាយតម្លៃបាន ឬក៏មិនអាចកាត់បន្ថយបានពីការខូចខាតដោយផ្ទាល់ចំពោះសេដ្ឋកិច្ច។ **<u>ទី២៖</u>** *យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ <u>ត្រូវតែលើកកម្ពស់កិច្ចសហការ និងកិច្ចសហប្រតិបត្តិការនៅក្នុងរដ្ឋាភិបាល</u> <u>ក៏ដូចជារវាងរដ្ឋាភិបាលនានា</u> <u>ដើម្បីឆ្លើយតបឱ្យបានរហ័ស</u> <u>និងមានប្រសិទ្ធភាពទៅនឹងការរាតត្បាតថ្មីៗ</u> <u>និងផ្លូវចម្លងរបស់ការរាតត្បាតនោះ</u>*។ កិច្ចសហការ នឹងជួយកិច្ចការពារ និងគាំពារប្រភពធនធានសម្រាប់គាំទ្រវិស័យសំខាន់ៗរួមមាន កសិកម្ម ជលផល ព្រៃឈើ សត្វព្រៃ និងប្រភេទក្នុងស្រុក។ ភាពកម្សោយ និងការមិនយល់ច្បាស់ពីតួនាទី និងភារកិច្ច អាចនាំឱ្យមានការយឺតយ៉ាវដល់ការឆ្លើយតបទៅនឹងការលេចឡើងនូវផ្លូវចម្លងថ្មីៗ។ ស្ថាប័ន និងអង្គភាពរដ្ឋភាគច្រើន មិនមានកម្មវិធីកសាងសមត្ថភាព និងថវិកាចាំបាច់ តែក៏មានកម្មវិធីដែលមានស្រាប់មួយចំនួន មិនមានភាពស៊ីសង្វាក់គ្នារវាងដែនសមត្ថកិច្ច ឬមិនមានសមត្ថភាពគ្រប់គ្រាន់។ **<u>ទី៣៖</u>** *យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ <u>ត្រូវតែពង្រឹងកម្មវិធីការពារ និងគាំពារប្រភពធនធានធម្មជាតិ និងធនធានជីវៈចម្រុះដែលបានគាំទ្រវិស័យសេដ្ឋកិច្ចជាតិ កំពុងទទួលរងសម្ពាធពីការធ្វើពាណិជ្ជកម្មអន្តរជាតិ និងការឆ្លងកាត់ផ្ទៃប្រទេស</u>*។ សមត្ថភាព គឺជាកត្តាគន្លឹះក្នុងការគ្រប់គ្រងប្រភេទរាតត្បាត។ ស្ថាប័ន និងអង្គភាពរដ្ឋ ដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងធនធានធម្មជាតិ មិនមាន

សមត្ថភាព និងជំនាញល្មមគ្រប់គ្រាន់ក្នុងការកំណត់រកអត្តសញ្ញាណប្រភេទរាតត្បាត ដែលកំពុងមានវត្តមាននៅក្នុងប្រទេសឱ្យបានសុក្រឹត្យច្បាស់លាស់។

១.២. វិសាលភាព

ប្រភេទរាតត្បាត ផ្តោតទៅលើមីក្រូសរីរាង្គ រុក្ខជាតិ និងសត្វ ដែលកំពុងមានវត្តមាន និងដែលអាចមានសក្តានុពលអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននៃប្រទេសកម្ពុជា។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ សំដៅចំពោះផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលបណ្តាលមកពីប្រភេទរាតត្បាតមានវត្តមានទាំងលើដីគោក និងក្នុងទឹក។ ឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះ មិនមានចេតនាដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធទៅនឹងមនុស្ស និងសត្វឡើយ បើទោះវាមានទំនាក់ទំនងគ្នាទៅវិញទៅមករវាងមនុស្ស សត្វ ប្រភេទរាតត្បាត និងការកើតមានជម្ងឺឆ្លងពីប្រភេទរាតត្បាតទៅលើមនុស្ស និងសត្វ។

## ២. ចក្ខុវិស័យ

ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជា នឹងមានភាពប្រសើរឡើងតាមរយៈការគ្រប់គ្រងប្រភេទរាតត្បាតនានាប្រកបដោយប្រសិទ្ធភាពត្រឹមឆ្នាំ២០២៥។

## ៣. បេសកកម្ម

ក្របខ័ណ្ឌគោលនយោបាយ និងយន្តការគ្រប់គ្រងប្រភេទរាតត្បាត ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធត្រូវបានបង្កើតឡើងសំដៅកាត់បន្ថយហានីភ័យទៅលើធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅត្រឹមឆ្នាំ២០២៥។

## ៤. គោលបំណង

គោលបំណងនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ គឺដើម្បី៖

- កំណត់វិធានការណ៍សមស្របសម្រាប់រារាំង ទប់ស្កាត់ លុបបំបាត់ ត្រួតត្រា តាមដាន និងគ្រប់គ្រងប្រភេទរាតត្បាត
- បង្កើនការយល់ដឹងពីប្រភេទរាតត្បាតដែលជាបញ្ហាចំបងបង្កផលប៉ះពាល់ដល់បរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា
- ពង្រឹងកិច្ចសហការណ៍ កិច្ចសហប្រតិបត្តិការណ៍ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រងប្រភេទរាតត្បាត។

## ៥. ក្របខ័ណ្ឌជាយុទ្ធសាស្ត្រ

៥.១. គោលការណ៍គ្រឹះសម្រាប់គ្រប់គ្រងប្រភេទរាតត្បាត

- ការគ្រប់គ្រងប្រភេទរាតត្បាត គឺជាផ្នែកមួយនៃការគ្រប់គ្រងធនធានធម្មជាតិ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានប្រកបដោយនិរន្តរភាព ដែលតម្រូវធ្វើសមាហរណកម្ម និងអនុវត្តវិធីសាស្ត្រចម្រុះ
- ការរារាំង និងការទប់ស្កាត់ គឺជាជម្រើសដ៏មានប្រសិទ្ធភាព និងប្រសិទ្ធផល សម្រាប់បង្កាលើការរាតត្បាតរបស់ប្រភេទក្រៅស្រុកនាំចូលដែលមិនទាន់មានវត្តមាននាពេលបច្ចុប្បន្ននេះ
- យន្តការសម្របសម្រួលកម្រិតជាតិ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ និងវិធីដោះស្រាយលើការគ្រប់គ្រងប្រភេទរាតត្បាត ដើម្បីជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព

- ការកំចាត់ប្រភេទរាតត្បាតឱ្យបានជោគជ័យ តម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសម្ចាស់កម្មសិទ្ធនៃទីតាំងដី និងអ្នកគ្រប់គ្រងដីស្រែចំការ ឬបរិវេណដីផ្សេងៗដែលមានប្រភេទរាតត្បាត
- ការទប់ស្កាត់ដ៏សកម្ម ឬការអនុវត្តនយោបាយដ៏តឹងរឹង មិនអាចរារាំងផ្លូវចម្លង ឬការសាយភាយរបស់ប្រភេទរាតត្បាតបានទាំងស្រុងនោះទេ
- ការគ្រប់គ្រងប្រភេទរាតត្បាតឱ្យមានប្រសិទ្ធភាព ត្រូវមានការគាំទ្រថវិកាជាតិ ពីវិស័យឯកជន និងពីសង្គមស៊ីវិល
- ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីចងក្រងព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សំដៅធានាដល់ការវាយតម្លៃ និងធានាដល់កម្មវិធីគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងមានវិទ្យាសាស្ត្រជាមូលដ្ឋាន។

### ៤.២. ទិសដៅជាយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយផលប៉ះពាល់របស់ប្រភេទរាតត្បាតទៅលើជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

ទិសដៅជាយុទ្ធសាស្ត្រដ៏ទូលំទូលាយ សម្រាប់កាត់បន្ថយផលប៉ះពាល់របស់ប្រភេទរាតត្បាតទៅលើធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ដែនជម្រក និងប្រភេទដីប្រើប្រាស់នានា អាចចែកចេញជាបួនវិធានការណ៍៖

**<u>វិធានការណ៍ទី១៖</u>** ការរារាំង ឬការបង្កាទៅលើសកម្មភាពនាំឱ្យកើតមាន និងការនាំចូលប្រភេទរាតត្បាតនៅមុនពេលប្រភេទរាតត្បាតទាំងនោះមានវត្តមាន ឬដុះ និងរស់នៅក្នុងទីតាំងថ្មី។

**<u>វិធានការណ៍ទី២៖</u>** ការផ្តល់សញ្ញាបន្ទាន់ និងការធ្វើអន្តរាគមន៍ឆ្លើយតបភ្លាមៗ រួមទាំងការលុបបំបាត់ទាំងស្រុង បើសិនជាអាចធ្វើទៅបាន។

**<u>វិធានការណ៍ទី៣៖</u>** ការត្រួតត្រា និងការគ្រប់គ្រងនៃប្រភេទរាតត្បាតក្នុងក្របខ័ណ្ឌបញ្ឈប់ការរាលដាលបន្ត។

**<u>វិធានការណ៍ទី៤៖</u>** ការស្តារឡើងវិញទីតាំង តំបន់ ដែនជម្រក ឬដីប្រើប្រាស់នានា ដែលទទួលរងការគំរាមកំហែង ឬការរិចរិលដោយសារប្រភេទរាតត្បាត។

#### ៤.២.១. វិធានការណ៍សម្រាប់រារាំង ឬបង្កា

ការរារាំង ឬការបង្កាទៅលើសកម្មភាពនាំឱ្យកើតមាន ឬការនាំចូលនៃប្រភេទរាតត្បាត គឺជាជម្រើសដ៏ប្រសើរបំផុតព្រោះសកម្មភាពនេះ វាមានប្រសិទ្ធភាព ព្រមទាំងមានប្រសិទ្ធផល សម្រាប់ការត្រួតពិនិត្យ និងការគ្រប់គ្រងប្រភេទរាតត្បាតមុនពេលមានវត្តមានរបស់ពួកវា និងចាត់ទុកជាសកម្មភាពយុទ្ធសាស្ត្រដែលមានអាទិភាពខ្ពស់បំផុត។

ជាការប្រសើរ គេមិនត្រូវធ្វើឱ្យកើតមាន ឬមិនត្រូវឱ្យមានការនាំចូលប្រភេទរាតត្បាតចូលក្នុងប្រទេសកម្ពុជាដោយមិនបានពិនិត្យឆែកឆេរជាមុន មិនបានធ្វើកូតតាមអនាម័យ និងមិនទាន់បានសិក្សាវាយតម្លៃពីហានិភ័យនៃការរាតត្បាតរបស់ប្រភេទទាំងនោះជាមុនបានឡើយ។ ជាការពិត វិធានការណ៍ទាំងនេះ គឺវាអាស្រ័យទៅនឹងការរៀបចំឱ្យមានផែនការទប់ស្កាត់បង្កាជាមុន ការលើកទឹកចិត្តដល់សមត្ថកិច្ចនានា និងអ្នកពាក់ព័ន្ធ និងការធ្វើឱ្យមានមធ្យោបាយសមស្របសម្រាប់ត្រួតពិនិត្យឆែកឆេរ។

គេមានការលំបាកជាខ្លាំងក្នុងការត្រួតត្រាលើការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត។ វិធានការណ៍អនុវត្តជាទូទៅ គឺត្រូវកំណត់រកអត្តសញ្ញាណ ត្រួតត្រា និងតាមដានផ្លូវចម្លងសំខាន់ៗដើម្បីកាត់បន្ថយការធ្វើឱ្យកើតមាន ឬការនាំចូលដោយអចេតនា។ ផ្លូវចម្លងសំខាន់ៗនៃប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដោយអចេតនាមកក្នុងប្រទេសកម្ពុជា គឺតាមរយៈពាណិជ្ជកម្ម សកម្មភាពអភិវឌ្ឍន៍ និងទេសចរណ៍ជាតិ និងអន្តរជាតិ នៅតាមច្រកចេញចូលអន្តរជាតិសំខាន់ៗ។

**គោលការណ៍ណែនាំសម្រាប់រារាំង ឬបង្ការនៃប្រភេទរាតត្បាត**

- ត្រូវរារាំង បង្ការ និងហាមឃាត់មុនពេលប្រភេទរាតត្បាត បានឆ្លងចូលមកដល់កម្ពុជា ព្រោះថាគេមិនអាចទស្សន៍ទាយទុកជាមុនអំពីផលប៉ះពាល់អវិជ្ជមាននៃប្រភេទរាតត្បាតទាំងនោះ ទៅលើជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ក្រោយពេល ប្រភេទទាំងនោះ មានវត្តមានរួចជាស្រេចនៅក្នុងប្រទេសកម្ពុជា
- ត្រូវគិត និងចាត់ទុកប្រភេទក្រៅស្រុកនានា អាចបង្កឱ្យមានហានីភ័យទៅថ្ងៃអនាគតនៅក្នុងកំរិតណាមួយ
- ត្រូវអនុវត្តគោលការណ៍ "**អ្នកបំពុលត្រូវទទួលខុសត្រូវចំពោះការធ្វើឱ្យកើតមានការពុល**"(Polluter Pays) ដែលសំដៅដល់ការធ្វើឱ្យខូចខាតជីវសាស្ត្រធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។ គោលការណ៍នេះត្រូវបានគេអនុវត្តចំពោះការឆ្លើយតបទៅនឹងការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទរាតត្បាតដោយអចេតនា ព្រោះប្រភេទរាតត្បាតនេះ អាចដើរតួនាទីជាអ្នកបំពុលជីវសាស្ត្រ ដែលបង្កផលប៉ះពាល់អវិជ្ជមានដល់ការអភិវឌ្ឍ និងគុណភាពនៃជីវិតទៅថ្ងៃអនាគត
- ត្រូវព្យាយាមកាត់បន្ថយហានីភ័យបណ្តាលមកពីការធ្វើឱ្យកើតមាន ឬការនាំចូលដោយអចេតនានៃប្រភេទក្រៅស្រុកនានា
- អាចធ្វើឱ្យកើតមាន ឬនាំចូលដោយអចេតនាទៅបានដ៏រាបណា ប្រភេទក្រៅស្រុកទាំងនោះ ត្រូវបានទទួលការអនុញ្ញាតពីស្ថាប័ននិងអង្គភាពមានសមត្ថកិច្ចជំនាញជាមុនសិន។ ការអនុញ្ញាតនេះ តម្រូវឱ្យស្ថាប័នសមត្ថកិច្ចជំនាញធ្វើការសិក្សាវាយតម្លៃពេញលេញ ទៅលើហានីភ័យនៃប្រភេទក្រៅស្រុកដែលត្រូវនាំចូល។ ប្រសិនបើគ្មានការអនុញ្ញាត គេត្រូវរារាំងទប់ស្កាត់ជាដាច់ខាតនូវរាល់សកម្មភាពធ្វើឱ្យកើតមាន ឬការនាំចូលនៃប្រភេទក្រៅស្រុក
- ប្រសិនបើចាំបាច់ត្រូវឱ្យមានការនាំចូលប្រភេទក្រៅស្រុកដោយខានមិនបាន គេចាំបាច់ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ សម្រាប់រៀបចំយុទ្ធសាស្ត្រ និងវិធានការថ្មីៗ ដើម្បីដោះស្រាយ និងឆ្លើយតបតាមការចាំបាច់
- ការរារាំងដ៏មានប្រសិទ្ធ ក៏អាស្រ័យទៅនឹងការរឹតបន្តឹងលើការនាំចូល និងការធ្វើចរាចរក្នុងផ្ទៃប្រទេសនៃប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត។ សកម្មភាពនេះ គឺជាកត្តាសំខាន់ក្នុងការគាំទ្រយុទ្ធសាស្ត្ររារាំង និងការកំចាត់នៃការរាលដាលទៅតំបន់ផ្សេងៗទៀត។

### ៥.២.២. វិធានការណ៍សម្រាប់ផ្តល់សញ្ញាបន្ទាន់ និងឆ្លើយតបឆ្លាមៗ

បើទោះជាមានកិច្ចខិតខំលើកិច្ចការរារាំងទប់ស្កាត់បានប្រសើរក្តី ក៏គេមិនអាចបញ្ឈប់រាល់ការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត ទាំងស្រុងបានឡើយ។ ការផ្តល់សញ្ញាបន្ទាន់នៃការចាប់ផ្តើមរាតត្បាត និងការឆ្លើយតប ក្រោមកិច្ចសហការណ៍ និងអន្តរាគមន៍ភ្លាមៗ គឺជាកត្តាចាំបាច់បំផុតដើម្បីឈានទៅលុបបំបាត់ ឬកំចាត់ចោលប្រភេទរាតត្បាតណាមួយ មុនពេលប្រភេទនោះ អាចរីករាលដាលហួសពីដែនសមត្ថភាព និងដែនសមត្ថកិច្ច រួមទាំងថវិកា និងវិធីសាស្ត្រត្រួតត្រាដែលមាន។ ថ្វីបើការផ្តល់សញ្ញាបន្ទាន់ និងការឆ្លើយតបភ្លាមៗជាយុទ្ធសាស្ត្រសំខាន់មួយនៃការគ្រប់គ្រងប្រភេទរាតត្បាត នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅមិនទាន់មានប្រព័ន្ធថ្នាក់ជាតិពេញលេញណាមួយ សម្រាប់ធ្វើការកត់សំគាល់អត្តសញ្ញាណ ឆ្លើយតប និងតាមដានលើការរាតត្បាតដែលទើបនឹងកើតមានឡើយ។ ប្រព័ន្ធឬយន្តការនេះ ត្រូវតែបង្កើតឡើងដើម្បីតាមដានប្រភេទក្រៅស្រុក ឬប្រ

ភេទរាតត្បាតនាំចូលដោយចេតនា ដែលបានផ្តល់សញ្ញារាតត្បាត និងត្រូវរៀបចំចាត់វិធានការកំចាត់ដល់ទីកន្លែង ដែលមានវត្តមានប្រភេទនោះ។

**គោលការណ៍ណែនាំសម្រាប់ផ្តល់សញ្ញាបន្ទាន់ និងឆ្លើយតបឆ្លាមៗ**

- ការផ្តល់សញ្ញាបន្ទាន់អំពីវត្តមានថ្មីៗរបស់ប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត និងសក្តានុពលរាតត្បាតរបស់វា គឺជាយុទ្ធសាស្ត្រគន្លឹះនៃការលុបបំបាត់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល គួបផ្សំនឹងសមត្ថភាពដោះស្រាយបញ្ហាជាបន្ទាន់
- ការប្រើប្រាស់វិធានអ្វីមួយជាចាំបាច់ ដើម្បីធ្វើការពន្យា ឬឃុំគ្រងឱ្យប្រភេទរាតត្បាតនៅមួយកន្លែង បើទោះជាមានភាពខ្វះខាតផ្នែកព័ត៌មានវិទ្យាសាស្ត្រ ឬសេដ្ឋកិច្ចអំពីឥទ្ធិពលរីករាលដាលជីវសាស្ត្រក៏ដោយ
- ការកំចាត់ ឬការឃុំគ្រងប្រភេទរាតត្បាត ត្រូវធ្វើនៅពេលប្រភេទរាតត្បាតទើបចាប់ផ្តើមរាតត្បាត គឺនៅពេលវាមានចំនួន និងទំហំតិចតួច និងមិនទាន់អាចបន្តពូជបាន
- ការកំចាត់ប្រភេទរាតត្បាតនៅដំណាក់ការដំបូង ជាពិសេសចំពោះការរកឃើញករណីថ្មីៗ គឺមានប្រសិទ្ធភាព និងប្រសិទ្ធផល ជាជាងការត្រួតត្រាវាក្នុងរយៈពេលវែង
- មិនត្រូវធ្វើសកម្មភាពលុបបំបាត់ទៅលើការរាតត្បាតទាំងស្រុងឡើយ ប្រសិនបើគេមិនទាន់បានធ្វើការសិក្សាពីអេកូឡូស៊ី និងមិនមានការប្តេជ្ញាចិត្តដោយមានថវិកាគាំទ្រសម្រាប់អនុវត្តសកម្មភាពនោះទេ
- ការត្រួតពិនិត្យឆែកឆេររកប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត នៅតាមព្រលានយន្តហោះ និងទីតាំងច្រកចេញចូលប្រទេសតាមព្រំប្រទល់ប្រទេស គឺជាវិធានការណ៍ដែលបានណែនាំផងដែរ។

**៥.២.៣ វិធានការណ៍សម្រាប់ត្រួតត្រា និងគ្រប់គ្រង**

ប្រសិនបើគេមិនអាចលុបបំបាត់ប្រភេទរាតត្បាតទាំងស្រុងបានទេ នៅពេលនោះគេនឹងត្រូវគ្រប់គ្រងប្រភេទរាតត្បាតទាំងនោះជារៀងរហូត ក្រោមវិធានការណ៍ត្រួតត្រាដ៏សមស្របមួយ។ បទពិសោធន៍នៅប្រទេសដែលមានស្ថានភាពប្រហាក់ប្រហែលកម្ពុជា បានបង្ហាញថាការលុបបំបាត់ប្រភេទរាតត្បាតទាំងស្រុង ទទួលបានជោគជ័យតិចតួច នៅក្រោមកម្មវិធីគ្រប់គ្រង។

**គោលការណ៍ណែនាំសម្រាប់ត្រួតត្រា និងគ្រប់គ្រង**

- ការអនុវត្តវិធានការត្រួតត្រាមានប្រសិទ្ធភាព ធ្វើទៅបានជរាបណាសង្គម វប្បធម៌ និងសីលធម៌អាចទទួលយកបានពោលគឺ គេត្រូវធ្វើការថ្លឹងថ្លែងធៀបទៅនឹងទស្សនៈយល់ដឹងនៃការមិនចាត់វិធានការណ៍អ្វីសោះទៅលើប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតទាំងនោះ
- ការអនុវត្តវិធានពិសេសដោយឡែក ពេលខ្លះអាចមានភាពប្រសើរជាងការអនុវត្តវិធានការណ៍រួមបញ្ចូលគ្នា។ ពេលខ្លះការប្រើភ្នាក់ងារសេរីរាង្គរស់ត្រួតត្រាជីវសាស្ត្រ(ប្រភេទរាតត្បាត) អាចមានភាពប្រសើរជាង បើធ្វើការប្រៀបធៀបជាមួយនឹងវិធានរូបសាស្ត្រ និងវិធានគីមីសាស្ត្រចូលគ្នា ក៏ប៉ុន្តែវាតម្រូវឱ្យមានការពិនិត្យហើយពិនិត្យទៀត មុនពេលសម្រេចអនុវត្តវិធានប្រើភ្នាក់ងារសេរីរាង្គរស់ត្រួតត្រាជីវសាស្ត្រ ដើម្បីកាត់បន្ថយជាអតិបរមានៃហានីភ័យទៅថ្ងៃក្រោយ
- សកម្មភាពសំអាតប្រភេទរាតត្បាតនៅលើផ្ទៃដីធំដោយប្រើកម្លាំង (រូបសាស្ត្រ) អាចជាជម្រើសដ៏មានប្រសិទ្ធភាព ក៏ប៉ុន្តែវាមានតម្លៃថ្លៃ និងត្រូវការពេលវេលា

- ត្រូវមានភាពច្បាស់លាស់ និងប្រាកដប្រជា នៅពេលណាត្រូវប្រើសារធាតុគីមី ដើម្បីជៀសវាងការបង្ក ឱ្យមានភាពធន់ (persistent) និងការធ្វើឱ្យមានភាពគរទុកនៃសារធាតុគីមី (accumulation) នៅក្នុងសង្វាក់បណ្ដាញចំណីអាហារក្នុងដី ឬក្នុងប្រព័ន្ធអេកូឡូស៊ី។ សារធាតុពុលមានក្នុងអង្គធាតុសរីរាង្គ (contaminant) រួមទាំងសមាសធាតុអង្គធាតុក្លរ មិនគួរយកមកប្រើប្រាស់ឡើយ
- គួរតែលើកទឹកចិត្ត និងជម្រុញឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន យុវជន និងស្ត្រី នៅក្នុងសកម្មភាពត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត
- ត្រូវអនុវត្តវិធីសាស្ត្រចំរុះជំនាញក្នុងការត្រួតត្រា និងការគ្រប់គ្រងនៃប្រភេទរាតត្បាត ប្រសិនបើចាំបាច់
- ត្រូវចាត់ទុកការអនុវត្តច្បាប់ និងបទដ្ឋាននានាដែលពាក់ព័ន្ធទៅនឹងប្រភេទរាតត្បាត គឺជាផ្នែកមួយនៃកម្មវិធី និងសកម្មភាពត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត។

#### ៥.២.៤. វិធានការណ៍សម្រាប់ស្ដារឡើងវិញ

**គោលការណ៍ណែនាំសម្រាប់ត្រួតពិនិត្យ និងគ្រប់គ្រង**

- ត្រូវតែកំណត់រកអត្តសញ្ញាណ និងកំណត់អាទិភាពប្រភេទរាតត្បាតដែលមានវត្តមាន មុនឈានដល់ការស្ដារទីកន្លែងដែលខូចខាត ឬរិចរិលដោយសារប្រភេទរាតត្បាតទាំងនោះ
- ត្រូវតែដាក់បញ្ចូលការរៀបចំ និងការអនុវត្តកម្មវិធីស្ដារទៅក្នុងកម្មវិធីរបស់វិស័យនានានៅគ្រប់កម្រិត
- ស្ថាប័នមានសមត្ថកិច្ចរដ្ឋដែលពាក់ព័ន្ធនានា មានតួនាទីក្នុងការដឹកនាំអ្នកពាក់ព័ន្ធផ្សេងៗឱ្យមកជួបជុំគ្នាដើម្បីចែករំលែកបទពិសោធន៍ក្នុងសកម្មភាព ឬកម្មវិធីនៃការស្ដារឡើងវិញ។

## ៦. ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិក្នុងក្របខ័ណ្ឌគោលនយោបាយ

ខាងក្រោមនេះ គឺជាកត្តាចាំបាច់សម្រាប់ការអនុវត្តន៍ឱ្យបានជោគជ័យនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីប្រភេទរាតត្បាត។

### ៦.១. ការកសាងសមត្ថភាពសម្រាប់រារាំង និងគ្រប់គ្រងប្រភេទរាតត្បាត

#### ៦.១.១. ការកសាងធនធានមនុស្ស

- ពង្រឹង និងបង្កើតស្ថាប័ន ឬក្រុមជំនាញបច្ចេកទេសដើម្បីគ្រប់គ្រងប្រភេទរាតត្បាត
- កសាងសមត្ថភាព និងជំនាញពាក់ព័ន្ធដើម្បីរៀបចំអនុវត្តកម្មវិធីអប់រំក្នុងការរារាំង ការផ្ដល់សញ្ញាបន្ទាន់ ការឆ្លើយតបភ្លាមៗ ការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត
- បណ្ដុះបណ្ដាលដល់មន្ត្រីជំនាញពាក់ព័ន្ធអំពីការកំណត់អត្តសញ្ញាណ ផ្លូវចម្លង សារពើភ័ណ្ឌ សុវត្ថិភាព ការទុកដាក់ ការដឹកជញ្ជូន ការបោះបង់ចោលប្រភេទរាតត្បាត និងភូតគាមអនាម័យ
- បញ្ជ្រាបប្រភេទរាតត្បាតទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ។
- បន្តពង្រឹងសមត្ថភាពស្ថាប័នជំនាញទទួលខុសត្រូវ សហគមន៍មូលដ្ឋាន និងក្រុមនានាដើម្បីអនុវត្តវិធានការណ៍គ្រប់គ្រងប្រភេទរាតត្បាត ដែលកំពុងមានវត្តមាន។

### ៦.១.២. ការពង្រឹងក្របខ័ណ្ឌស្ថាប័ន និងកិច្ចសហការណ៍រវាងស្ថាប័ន

លើកទឹកចិត្តលើការស្រាវជ្រាវអំពីប្រភេទរាតត្បាត ជាពិសេសពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងជីវសាស្ត្រ ការកំណត់រកឈ្មោះ និងការចាត់លំដាប់ថ្នាក់នៃប្រភេទ និងអេកូឡូស៊ីនៅទូទាំងប្រទេស

- ផ្តល់ឧបករណ៍បរិក្ខារគ្រប់គ្រាន់សម្រាប់មន្ទីរពិសោធន៍ទៅលើប្រភេទរាតត្បាត ជាពិសេស នៅតាមវិទ្យាស្ថានជាន់ខ្ពស់
- កសាងបណ្តាញស្រាវជ្រាវដែលអាចបញ្ជ្រាបការវាយតម្លៃហានិភ័យ និងបច្ចេកទេសគ្រប់គ្រងហានិភ័យ
- តម្រែតម្រង់ទិសនៃធនធានស្រាវជ្រាវដែលមានស្រាប់ ដើម្បីឆ្ពោះទៅរកប្រភេទរាតត្បាតតាមរយៈការផ្សព្វផ្សាយព័ត៌មាន និងមានការចូលរួមពីគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានស្រាវជ្រាវជាតិ
- បង្កើតក្រុមបណ្ឌិតសភា ឬក្រុមអ្នកវិទ្យាសាស្ត្រអំពីជីវសាស្ត្រនៃការរាតត្បាត និងលើកទឹកចិត្តឱ្យមានការដោះដូរ កិច្ចសហការ និងកិច្ចសហប្រតិបត្តិការក្នុងការបង្កើតអភិក្រមស្រាវជ្រាវផ្សេងៗ
- កសាង និងគាំទ្រយន្តការនៃកិច្ចសហការ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព សម្រាប់រាំង ផ្តល់សញ្ញា ឆ្លើយតប ត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាតនៅក្នុងប្រទេស
- ផ្តល់អំណាចដល់ស្ថាប័នសម្របសម្រួល ឬដល់យន្តការចាត់តាំងសមស្របណាមួយ ដើម្បីឈានដល់ការធ្វើសេចក្តីសម្រេចចិត្ត ថាតើសំណើនាំចូល ឬការធ្វើឱ្យកើតមានប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត គួរតែអនុញ្ញាតដែរឬទេ
- ពង្រឹងសមត្ថភាពស្ថាប័នលើការត្រួតត្រា និងការឃ្លាំមើលនៅទីតាំងយុទ្ធសាស្ត្រ មានជាអាទិ៍ កំពង់ផែ និងច្រកចេញចូលតាមព្រំប្រទល់នៃប្រទេស
- រៀបចំយន្តការកាត់បន្ថយ និងយន្តការតាមដានប្រភេទរាតត្បាតតាមរយៈការសិក្សាស្រាវជ្រាវ និងគ្រប់គ្រងតាមវិស័យនានា។

## ៦.២. ឧបករណ៍ និងយុទ្ធសាស្ត្រ

### ៦.២.១. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់រារាំង

- កំណត់រកអត្តសញ្ញាណ កត់ត្រា និងផ្សព្វផ្សាយប្រភេទរាតត្បាតបង្កហានិភ័យ
- កំណត់រកអត្តសញ្ញាណ និងគ្រប់គ្រងផ្លូវចម្លងដែលនាំឱ្យកើតមាន ឬនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដោយអចេតនា ឧទាហរណ៍ តាមរយៈការធ្វើពាណិជ្ជកម្មអន្តរជាតិ ច្រកចេញចូលតាមព្រំដែន សកម្មភាពទេសចរណ៍ វិស័យព្រៃឈើ វិស័យជលផល វិស័យកសិកម្ម គម្រោងវិស្វកម្ម មធ្យោបាយធ្វើដំណើរជើងគោក តាមជើងយន្តហោះ វិស័យបង្កាត់ពូជ និងវិស័យវារីសាស្ត្រ
- សិក្សាស្រាវជ្រាវ និងគាំទ្រការស្រាវជ្រាវ ដើម្បីពង្រឹងការយល់ដឹងអំពីមូលហេតុដែលនាំឱ្យកើតមានប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដែលមានវត្តមាននៅទីតាំងថ្មី និងស៊ើបអង្កេតប្រភេទក្រៅស្រុកដែលមានសក្តានុពលរាតត្បាត ហើយប្រព័ន្ធអេកូឡូស៊ីនានាដែលងាយរងគ្រោះថ្នាក់ដោយសារការរាលដាលនៃប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតទាំងនោះ
- រៀបចំគោលការណ៍ណែនាំក្នុងក្របខ័ណ្ឌសហការណ៍ជាមួយវិធានអនុវត្តជាក់ស្តែង ដែលសំដៅកាត់បន្ថយវត្តមានប្រភេទរាតត្បាតក្នុងកម្រិតអតិបរមា ឬឈានទៅលុបបំបាត់ការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដោយអចេតនា
- ផ្សព្វផ្សាយជាសាធារណៈឱ្យប្រតិបត្តិនូវវិធានអនុវត្តជាក់ស្តែង ដែលពាក់ព័ន្ធនឹងការរារាំងប្រភេទរាតត្បាត

- ដាក់ឱ្យអនុវត្តនូវវិធានកូតតាមអនាម័យ ការត្រួតពិនិត្យតាមព្រំប្រទល់ ឬហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនានា ដើម្បីតាមដានការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត
- អនុវត្តផលប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ដើម្បីរាំងការរាតត្បាតរបស់ប្រភេទក្រៅស្រុក ដោយអចេតនា
- វាយតម្លៃហានីភ័យនៃប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដែលស្នើសុំនាំចូល មុនពេលធ្វើសេចក្តីសម្រេចចិត្តធ្វើការនាំចូល
- រៀបចំវិធីសាស្ត្រអនុវត្តសាកល្បងនៃវិធានប្រើសរីរាង្គរស់ត្រួតពិនិត្យជីវសាស្ត្រសមស្រប និងអនុវត្តសាកល្បងលើការត្រួតពិនិត្យប្រភេទរាតត្បាតដោយប្រើសត្រូវធម្មជាតិដើម្បីវាយតម្លៃ បើសិនជាចាំបាច់
- រៀបចំវិធីសាស្ត្រឱ្យបានប្រសើរសម្រាប់អនុវត្តចំពោះ ឬដកចេញប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតចេញពីទំនិញជួញដូរ សំភារៈវេចខ្ចប់ របស់របរធ្វើដំណើររបស់បុគ្គល តាមរយៈរថយន្ត យន្តហោះ និងមធ្យោបាយនានា
- លើកទឹកចិត្តដល់អ្នកធ្វើនីហរ័ណ និងអាហរ័ណឱ្យឆ្លើយតបទៅនឹងបទដ្ឋានប្រតិបត្តិល្អៗ សម្រាប់កាត់បន្ថយហានីភ័យនៃការរាតត្បាតក្នុងកម្រិតអប្បរមាដែលមានការពាក់ព័ន្ធទៅនឹងការជួញដូរ និងសម្រាប់ឃុំគ្រងនៃប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដែលអាចនឹងរួចផុតពីការត្រួតពិនិត្យដោយចៃដន្យ។

### ៦.២.២. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់ផ្តល់សញ្ញាបន្ទាន់ និងឆ្លើយតបឆាប់ៗ

- រៀបចំបង្កើតយន្តការផ្តល់សញ្ញាបន្ទាន់ និងឆ្លើយតបភ្លាមៗ ទៅនឹងវត្តមានប្រភេទរាតត្បាតប្រភេទរាតត្បាតប្រកបដោយហានីភ័យដែលទើបនឹងមានវត្តមាន។ យន្តការនេះតម្រូវះ
  - ➢ បង្កើតមូលនិធិដែលមានភាពងាយស្រួលក្នុងការយកមកប្រើប្រាស់ សម្រាប់សកម្មភាពសង្គ្រោះបន្ទាន់
  - ➢ គាំទ្រជាប្រចាំរាល់សកម្មភាពឆ្លើយតបភ្លាមៗ
  - ➢ សហការគ្រប់វិស័យដើម្បីអាចកំណត់អត្តសញ្ញាណបានរហ័ស
- រៀបចំ និងអនុវត្តប្រព័ន្ធសង្គ្រោះ ប្រព័ន្ធតាមដាន និងប្រព័ន្ធព្រមានដើម្បីឆ្លើយតបបានរហ័សក្នុងការកំណត់រកហេតុដែលធ្វើឱ្យកើតមាន ឬការនាំចូលនៃប្រភេទរាតត្បាត
- ជានាឱ្យមានការតាមដានប្រភេទរាតត្បាតនានាជាប្រចាំ ជាពិសេសសម្រាប់អ្នកអនុវត្តនៅទីវាល មានជាអាទិ៍ អ្នកបង្កាត់ពូជ អ្នកជីវវិទ្យា អ្នកអេកូឡូស៊ី និងបណ្តាអ្នកស្រាវជ្រាវ ដែលមានភារកិច្ចតាមដាន
- អនុវត្ត និងគាំទ្រការតាមដាន ការធ្វើកំណត់ត្រា និងការរាយការណ៍ ធ្វើដូចនេះគេអាចចងក្រងបទពិសោធន៍ល្អៗ ដែលកើតចេញពីការគ្រប់គ្រងប្រភេទរាតត្បាត ដើម្បីចូលរួមវិភាគទានដល់ចំណេះដឹងមូលដ្ឋាន
- គួរមានការតាមដានជាប្រចាំនៅតាមព្រលានយន្តហោះ ច្រកចេញចូលតាមជាយដែន និងស្ថានីយ៍ពិសោធន៍នានា
- ផ្តល់អាទិភាពដល់ការលុបបំបាត់ប្រភេទរាតត្បាតថ្មីៗដែលទើបកើតឡើង មុនពេលប្រភេទទាំងនោះដុះលូតលាស់ និងរីករាលដាលបន្ថែម
- ធានាថាវិធីលុបបំបាត់ ត្រូវមានភាពច្បាស់លាស់បំផុតជាមួយនឹងគោលបំណងមិនធ្វើមានផលប៉ះពាល់រយៈពេលវែងទៅលើប្រភេទក្នុងស្រុក។

### ៦.២.៣. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់ត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត

វិធីសាស្ត្រដ៏សមស្របបំផុតសម្រាប់ត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត គឺការពិចារណាទៅលើព័ត៌មានវិទ្យាសាស្ត្រដែលមានស្រាប់ និងទៅលើផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការអនុវត្តវិធីសាស្ត្របច្ចេកទេសប្រើប្រាស់ដើម្បីត្រួតត្រា។ វិធីសាស្ត្រទាំងនោះ មានការអនុវត្តបែបប្រពៃណី (ដូចជាការដាំដំណាំវិលជុំ) ការសង់របង ការជម្រះសម្អាត (ដូចជាការជម្រះសម្អាតដោយដៃ ដោយម៉ាស៊ីន ការដុតកំទេច ការលើកកំកិល) ការប្រើសារធាតុគីមី និងការលែងសត្វសត្រូវធម្មជាតិឱ្យស៊ីប្រភេទរាតត្បាត (ជីវសាស្ត្រ)។ ជានិច្ចកាល គេគួរប្រើវិធីសាស្ត្រខាងលើចម្រុះគ្នាសម្រាប់គោលដៅអ្វីមួយ។ ខាងក្រោមជាវិធីសាស្ត្រមួយចំនួនៈ

**ការត្រួតត្រាតាមរយៈកម្លាំងៈ** សំដៅដល់ការរើសម្អាតប្រភេទរាតត្បាតចេញដោយដៃ ដោយកម្លាំង ឬដោយមានជំនួយម៉ាស៊ីនសម្រាប់ធ្វើការសម្អាត (ឧទាហរណ៍ ការប្រមូលសម្អាតកំប្លោក)។

**ការត្រួតត្រាដោយប្រើសារធាតុគីមីៈ** សកម្មភាពនេះមានការពាក់ព័ន្ធទៅនឹងការប្រើប្រាស់សារធាតុគីមីកំចាត់ស្មៅ ឬថ្នាំសម្លាប់សត្វល្អិត ដែលមានប្រសិទ្ធិភាពខ្ពស់ចំពោះប្រភេទរាតត្បាត តែគេគួរតែជៀសវាងឱ្យខាងតែបាននូវសារជាតុគីមីណា ដែលអាចបង្កបញ្ហាភាពបន្សាំខ្លួននៅក្នុងដី ទឹក និងខ្យល់ក្នុងរយៈពេលវែង និងគេក៏គួរតែជៀសវាងសារជាតុគីមីណា ដែលអាចគរទុកនៅក្នុងបណ្តាញចំណីអាហារក្នុងដី ឬក្នុងប្រព័ន្ធអេកូឡូស៊ី។ ការវិវត្តទៅជាសារជាតុបន្សាំខ្លួនរបស់ថ្នាំសំលាប់សត្វល្អិត ថ្នាំកំចាត់ជម្ងឺ និងថ្នាំកំចាត់រុក្ខជាតិចង្រៃដែលកំពុងប្រើ អាចកាត់បន្ថយប្រសិទ្ធិភាពនៃការត្រួតត្រាលើប្រភេទរាតត្បាតដែលគេត្រូវកំចាត់ចោល។

**ការត្រួតត្រាដោយប្រើសរីរាង្គមានជីវិត(សត្រូវធម្មជាតិ)ៈ** ជាសកម្មភាពសំដៅដល់ការប្រើប្រាស់សត្រូវធម្មជាតិជាសរីរាង្គរស់ដោយចេតនាទៅលើប្រភេទរាតត្បាតណាមួយ ឬក៏ជាការប្រលែងសត្រូវធម្មជាតិនៃសរីរាង្គរស់ដើម្បីត្រួតត្រាប្រភេទរាតត្បាតណាមួយ។ ប្រការនេះគេអាចអនុវត្តទៅបាន ដរាបណាតែសរីរាង្គរស់ ឬសត្រូវធម្មជាតិដែលត្រូវយកមកប្រើប្រាស់ ឬលែងក្នុងធម្មជាតិ ត្រូវបានគេស្គាល់លក្ខណៈជីវសាស្ត្រជាក់លាក់ជាមុនសិន។

**ការគ្រប់គ្រងដែនជម្រកៈ** វិធាននេះមានការពាក់ព័ន្ធដល់វិធាននានាដូចជាប្រើការដុតកំទេច ការប្រើសត្វស៊ីប្រភេទរាតត្បាតធ្វើជាចំណី ឬក៏សកម្មភាពដែលមានសភាពប្រហាក់ប្រហែល ដើម្បីគាបសង្កត់ការលូតលាស់។

ផ្អែកលើវិធានការណ៍ត្រួតត្រាដែលមានស្រាប់នៅតាមមូលដ្ឋានជាក់ស្តែង ខាងក្រោមជាអនុសាសន៍សម្រាប់ចំណាត់ការផ្សេងៗៈ

- គេត្រូវរៀបចំធ្វើសារពើភ័ណ្ឌប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងពីការវាយលុករបស់ប្រភេទរាតត្បាត បន្ទាប់មកដាក់ចេញជាយុទ្ធសាស្ត្រត្រួតត្រាផ្លូវការ ដែលរួមទាំងការកំណត់ទីភ្នាក់ងារអនុវត្តជាមួយនឹងការព្រមព្រៀងទៅលើប្រភេទរាតត្បាតអាទិភាព ការកំណត់ទីតាំងសំរាប់ចំណាត់ការត្រួតត្រា វិធីសាស្ត្រ និងពេលវេលាអនុវត្ត
- ការវាយតម្លៃពីលទ្ធភាពបញ្ឈប់ការរីករាលដាលបន្ថែមទៀតរបស់ប្រភេទរាតត្បាត គឺជាយុទ្ធសាស្ត្រដ៏សមស្របបំផុត នៅពេលណាការកំចាត់ចោលទាំងស្រុងមិនអាចធ្វើទៅរួច។ ក៏ប៉ុន្តែនៅទីតាំងណាដែលប្រភេទរាតត្បាតទាំងនោះ មិនអាចរីករាលដាលបន្ត គេត្រូវអនុវត្តចំណាត់ការឃុំទុកប្រភេទរាតត្បាតនោះឱ្យនៅក្នុងតំបន់កំណត់មួយជាក់លាក់ណាមួយ
- ការវាយតម្លៃអំពីលទ្ធភាពកាត់បន្ថយនៃប្រភេទរាតត្បាតណាមួយក្នុងរយៈពេលវែង នឹងអាចទទួល

បានជោគជ័យតាមរយៈការកែសម្រួលទៅតាមស្ថានភាពនៃចំណាត់ការ ឬទៅតាមសកម្មភាពចំណាត់ការដែលពាក់ព័ន្ធ (សកម្មភាពត្រួតត្រាចម្រុះ)។ សកម្មភាពចំណាត់ការទោលដែលទទួលបានជោគជ័យ គឺមានតែការលែងសត្រូវធម្មជាតិនៃសរីរាង្គរស់ប៉ុណ្ណោះ ដែលជាវិធីសាស្ត្រគ្រប់គ្រង ឬត្រួតត្រា និងផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធអំពីការប្រើប្រាស់វិធីសាស្ត្រនានា ដែលបានជ្រើសរើសរួចហើយ និងអាចធ្វើទៅបាន

- សិក្សាស្រាវជ្រាវ និងគាំទ្រដល់ការស្រាវជ្រាវអំពីប្រសិទ្ធភាពនៃវិធីសាស្ត្រទៅលើប្រភេទច្បាស់លាស់ណាមួយ និងទៅលើមនុស្ស និងសង្គមសម្រាប់លុបបំបាត់ ឬត្រួតត្រាលើប្រភេទរាតត្បាត
- ស្រាវជ្រាវ និងគាំទ្រដល់ការស្រាវជ្រាវដើម្បីកំណត់រកកត្តារួមចំណែករបស់មនុស្ស កត្តាធម្មជាតិ និងសកម្មភាព អន្តរាគមន៍សម្រាប់ត្រួតត្រាទៅដល់ការរីកសាយភាយនៃប្រភេទរាតត្បាត
- សិក្សាស្រាវជ្រាវពីជីវសាស្ត្រនៃប្រភេទរាតត្បាត និងប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះពីប្រភេទរាតត្បាត។

### ៦.២.៤. ឧបករណ៍ និងយុទ្ធសាស្ត្រសម្រាប់ស្តារឡើងវិញ

- ធ្វើសារពើភ័ណ្ឌប្រព័ន្ធអេកូឡូស៊ីដែលទទួលរងផលប៉ះពាល់ពីប្រភេទរាតត្បាត
- ធ្វើចំណាត់ថ្នាក់អាទិភាពចំពោះទីតាំងណា ដែលមានវត្តមានប្រភេទរាតត្បាតសម្រាប់ស្តារឡើងវិញ
- រៀបចំតាក់តែងវិធីសាស្ត្រសម្រាប់ស្តារប្រព័ន្ធអេកូឡូស៊ី និងយុទ្ធសាស្ត្រធ្វើឱ្យមាននិរន្តរភាពនៃវិធានការណ៍
- ត្រួតត្រាផ្សេងៗ មានដូចជាការត្រួតត្រាដោយប្រើសត្រូវធម្មជាតិនៃសរីរាង្គរស់ ការត្រួតត្រាតាមរយៈកម្លាំង
- ការគ្រប់គ្រងចំរុះ ការប្រើភ្លើងដុត ឬការត្រួតត្រាដោយប្រើសារធាតុគីមីជាដើម
- ធានាឱ្យមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់កម្មវិធីស្តារឡើងវិញ
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់រុក្ខជាតិក្នុងស្រុកសម្រាប់ស្តារឡើងវិញ
- រៀបចំ និងអនុវត្តផែនការតាមដាន និងវាយតម្លៃលើការគ្រប់គ្រងប្រភេទរាតត្បាត
- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយដៃគូ និងអ្នកពាក់ព័ន្ធ ដើម្បីចែករំលែកបទពិសោធន៍អំពីសកម្មភាពស្តារឡើងវិញ
- គាំទ្រកិច្ចផ្តួចផ្តើមរបស់សហគមន៍ក្នុងការគ្រប់គ្រងប្រភេទរាតត្បាត។

## ៦.៣. ការគាំទ្រលើការគ្រប់គ្រងព័ត៌មាន និងការផ្សព្វផ្សាយ

កម្មវិធីប្រភេទរាតត្បាតសកល (Global Invasive Species Programme (GISP) និងប្រព័ន្ធប្រមូលប្រភេទរាតត្បាតឈ្មោះ Invasive Species Conpendium ក្រោមការគ្រប់គ្រងរបស់ CAB International ជាប្រភពព័ត៌មានសំខាន់ៗ និងអាចរកបានតាមរយៈប្រព័ន្ធអេឡិចត្រូនិក(អិនធឺណែត) នូវប្រភេទរាតត្បាតនានា។ ព័ត៌មានទាំងនោះ ក៏អាចយកមកធ្វើជាចំណេះដឹងមូលដ្ឋានសម្រាប់គ្រប់គ្រងប្រភេទក្រៅស្រុកនាំចូលថ្មីៗ ដែលមិនទាន់បានជ្រួតជ្រាបច្បាស់ ឬក៏មិនទាន់មានសមត្ថភាពគ្រប់គ្រង។

### ៦.៣.១ គោលការណ៍ណែនាំ

- ចងក្រងព័ត៌មានអំពីប្រភេទរាតត្បាត ដើម្បីយកព័ត៌មានទាំងនោះ ទៅគ្រប់គ្រងប្រភេទរាតត្បាតក្នុងប្រទេស

- ដោយសារការរៀបចំចំណាត់ថ្នាក់ជាអាទិភាពនៃរុក្ខជាតិរាតត្បាតសម្រាប់ត្រួតត្រានៅមានបញ្ហាច្រើន ជាការប្រសើរគេចាំបាច់ ត្រូវតែចាប់ផ្តើមចេញពីអនុវត្តទៅលើប្រភេទរាតត្បាតដែលមានអាទិភាពខ្ពស់ និងក្នុងបរិមាណតិចតួច
- ជានិច្ចកាលត្រូវតែធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីប្រមើលទុកជាមុនអំពីការរាតត្បាតនៃប្រភេទក្រៅស្រុកណាមួយ។ តារាងបញ្ជីឈ្មោះប្រភេទរាត្បាតមួយចំនួនដែលបានកំនត់ដោយអ្នកចូលរួមក្នុងសិក្ខាសាលា ថាជាប្រភេទអាទិភាពដែលត្រូវតែចាត់វិធានត្រួតត្រាជាបន្ទាន់ មានចែងនៅក្នុងឧបសម្ព័ន្ធទី៤
- ស្ថាប័នជាតិ សង្គមស៊ីវិល ផ្នែកឯកជន និងសហគមន៍មូលដ្ឋាន គួរមានភារកិច្ចចំបងលើការប្រមូលទិន្នន័យ និងព័ត៌មានអំពីប្រភេទរាត្បាត ព្រមទាំងបញ្ហាពាក់ព័ន្ធនានា
- គួរតែចែងឱ្យបានច្បាស់នៅក្នុងសៀវភៅណែនាំអំពីព័ត៌មាននៃប្រភេទរាតត្បាត ។

### ៦.៣.២. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង

- ផ្តួចផ្តើមរៀបចំចំណេះដឹងជាមូលដ្ឋាន ដែលចាំបាច់បំផុតសម្រាប់ដោះស្រាយបញ្ហាប្រភេទរាតត្បាតនានា ជាពិសេសសម្រាប់ប្រភេទរាតត្បាតដែលមានចែងក្នុងឧបសម្ព័ន្ធ៤ ដោយផ្តោតទៅលើទីកន្លែងអាចកើតមាន កម្រិតរាតត្បាត និងប្រសិទ្ធភាពនៃការត្រួតត្រាប្រភេទរាតត្បាតណាមួយ
- ភ្ជាប់ប្រព័ន្ធទិន្នន័យរុក្ខជាតិក្នុងប្រទេស តំបន់ និងសកលលោក (ឧទាហរណ៍ IUCN/ISSG, GISP, Aliens List Server, Invasive Species Compendium (ISC))។ ប្រព័ន្ធព័ត៌មានអំពីប្រភេទរាតត្បាតសកលលោក នឹងដើរតួនាទីជាមូលដ្ឋាននៃបណ្តាញចែកចាយ បង្កើតបទដ្ឋានទិន្នន័យ និងជួយសម្រួលដល់ការដាក់បញ្ចូល និងចែកចាយ
- រៀបចំបញ្ជីឈ្មោះប្រភេទរាតត្បាតទូទាំងប្រទេស
- លើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរព័ត៌មានរវាងអ្នកវិទ្យាសាស្ត្រ និងស្ថាប័នគ្រប់គ្រង មិនត្រឹមតែប្រភេទរាតត្បាត តែថែមទាំងវិធីសាស្ត្រត្រួតត្រាលើប្រភេទរាតត្បាតទាំងនោះផងដែរ
- រៀបចំចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីវិធីសាស្ត្រល្អៗសម្រាប់ដោះស្រាយបញ្ហាប្រភេទរាតត្បាតដែលកើតចេញពីទំនិញដូញដូរ ឬសម្ភារៈវេចខ្ចប់ស្រោចរបស់របរអ្នកធ្វើដំណើរ និងមធ្យោបាយធ្វើដំណើរ
- រៀបចំយន្តការចែកចាយ និងការដោះដូរព័ត៌មានអំពីការរារាំង ការលុបបំបាត់ និងការត្រួតត្រាប្រភេទរាតត្បាតក្នុងចំណោមអ្នកពាក់ព័ន្ធ
- រៀបចំយន្តការប្រមូល និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជនជាក់លាក់
- បង្កើតប្រព័ន្ធទិន្ន័យប្រភេទរាតត្បាតដោយបញ្ចូលព័ត៌មានអំពីហានីភ័យនៃប្រភេទរាតត្បាតនីមួយៗ និងចរិកលក្ខណៈនៃប្រភេទនីមួយៗដូចជា លក្ខណៈរូបសាស្ត្រ និងយន្តការគ្រប់គ្រងជាដើម។

## ៦.៤. ការចូលរួមរបស់សាធារណជនក្នុងការរារាំង និងការគ្រប់គ្រងប្រភេទរាតត្បាត

ការចូលរួមដ៏សកម្មរបស់សាធារណជន គឺជាកត្តាសំខាន់ណាស់ក្នុងការគ្រប់គ្រងប្រភេទរាតត្បាតឱ្យបានជោគជ័យ។ គេត្រូវតែមានចំណេះដឹង ផ្តល់ការអប់រំ និងជម្រាបជូនដល់សាធារណជន ដើម្បីឱ្យពួកគេអាចចូលរួមទទួលខុសត្រូវក្នុងការរារាំង ការត្រួតត្រា និងការគ្រប់គ្រប់ប្រភេទរាតត្បាត។ ចំណេះដឹងរបស់សាធារណៈ ដើម្បីបង្កើនការចូលរួម គួរមានគោលការណ៍ដូចខាងក្រោម៖

### ៦.៤.១. គោលការណ៍ណែនាំ

- ការផ្តល់ចំណេះដឹង និងការយល់ដឹងដោយផ្អែកលើព័ត៌មាន និងចំណេះវិជ្ជាអំពីការកើតឡើងនៃប្រភេទរាតត្បាត អំពីដំណោះស្រាយបញ្ហាទិភាពណាមួយ គឺជាកត្តាសំខាន់
- រកឱកាសដោះស្រាយបញ្ហារាតត្បាតដែលគេបានស្គាល់។ ត្រូវបង្កើនការយល់ដឹងដល់សាធារណជន និងចំណាត់ការជាសាធារណៈ តាមរយៈចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីប្រភេទដែលមានហានិភ័យខ្ពស់ គឺជាកត្តាអាទិភាព
- ពង្រឹងការយល់ដឹងជាសាធារណៈអំពីបញ្ហាប្រភេទរាតត្បាត គឺជាមូលដ្ឋានគ្រឹះនៃការរារាំង ឬការកាត់បន្ថយហានីភ័យនៃការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដោយអចេតនា ឬមិនមានការអនុញ្ញាត
- កម្មវិធីយល់ដឹងអំពីប្រភេទរាតត្បាត គួរផ្តោតទៅលើសាធារណជន និងឯកជន។ កិច្ចខិតខំប្រឹងប្រែងទៅលើកម្មវិធីយល់ដឹងអំពីប្រភេទរាតត្បាត គេគួរតែសង្កត់ធ្ងន់ទៅលើយុវជន ស្ត្រី និងក្រុមជនដែលងាយរងគ្រោះ
- គេគួរតែលើកទឹកចិត្ត ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអំពីការកង្វល់នៃប្រភេទរាតត្បាតទៅលើវិស័យនានា។

### ៦.៤.២. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង

- រៀបចំយុទ្ធនាការផ្សព្វផ្សាយដោយប្រើប្រាស់ព័ត៌មានថ្មីៗ និងច្បាស់លាស់អំពីប្រភេទរាតត្បាត
- ប្រើព័ត៌មានក្នុងទម្រង់ផ្សេងៗ មានជាអាទិ៍ អេឡិចត្រូនិក សៀវភៅណែនាំ ប្រព័ន្ធទិន្នន័យ ទស្សនាវដ្តី វិទ្យាសាស្ត្រ និងឧបករណ៍ផ្សព្វផ្សាយផ្សេងៗ ទៅតាមក្រុមគោលដៅដែលបានកំណត់ទុក
- លើកទឹកចិត្តផ្នែកឯកជន និងអ្នកពាក់ព័ន្ធឯទៀត ឱ្យអនុវត្តតាមសៀវភៅណែនាំអំពីបទពិសោធន៍ល្អៗ ឬនិតិវិធីសម្រាប់អនុវត្ត និងតាមដានដែលមានចែងក្នុងសៀវភៅណែនាំ
- ធានាថាសាធារណជន មានការយល់ដឹងច្បាស់លាស់អំពីការអនុវត្តបទដ្ឋានច្បាប់ចំពោះការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត ទោះបីដោយចេតនាក្តី ឬអចេតនាក្តី
- ផ្សព្វផ្សាយជាសាធារណអំពីសៀវភៅណែនាំស្តីពីយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ និងគោលនយោបាយជាតិអំពីការគ្រប់គ្រងប្រភេទរាតត្បាត
- បកប្រែសៀវភៅណែនាំស្តីពីយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ និងគោលនយោបាយគ្រប់គ្រងប្រភេទរាតត្បាតជាភាសាសាមញ្ញដែលមានភាពសមស្របទៅនឹងក្រុមគោលដៅ
- ប្រើប្រាស់កន្លែងបង្ហាញដែលសមស្របអំពីប្រភេទរាតត្បាតដែលជាអាទិភាពខ្ពស់ ឬនៅកន្លែងសាធារណៈដែលងាយមើលឃើញ ឬក៏ប្រភេទក្នុងស្រុកដែលទទួលរងផលវិបាកពីប្រភេទរាតត្បាត
- រៀបចំយុទ្ធសាស្ត្រអំពីការយល់ដឹងជាក់លាក់ និងទំនាក់ទំនង សម្រាប់ក្រុមគោលដៅនីមួយៗ ដើម្បីឱ្យពួកគេអាចជួយកាត់បន្ថយហានីភ័យដែលបង្កដោយប្រភេទរាតត្បាត។ សាធារណជន គឺជាក្រុមគោលដៅសំខាន់ ដែលត្រូវតែយកចិត្តទុកដាក់។

### ៦.៥. ការរៀបចំគោលនយោបាយសេដ្ឋកិច្ច

នាពេលបច្ចុប្បន្ន មានវិធានរារាំងមួយចំនួនទៅលើការនាំទំនិញចូល (អាហរណកម្ម) ឬការប្រើប្រាស់ប្រភេទរាតត្បាត និងបានបង្កឧបសគ្គរារាំងទៅលើអ្នកទាំងឡាយណាដែលធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត។ ឧបករណ៍ និងការលើកទឹកចិត្តល្អៗ ចាំបាច់ត្រូវតែរៀបចំអនុវត្តជាបន្ទាន់ រួមទាំងទំនួលខុសត្រូវក្នុងការដោះស្រាយផលប៉ះពាល់នៃប្រភេទរាតត្បាត ជាមួយគ្នានឹងការអនុវត្តយន្តការទូទាត់សំណងគ្រឿងលើកទឹកចិត្ត និងការលើកទឹកចិត្តដោយមិនផ្ទាល់ផងដែរ។ ប្រភេទរាតត្បាត ជានិច្ចកាល កើតចេញពីផលវិបាកនៃការសម្រេចចិត្តដើម្បីវិស័យសេដ្ឋកិច្ច វិស័យវិស្វកម្ម ឬវិស័យសន្តិសុខស្បៀង ហើយចុងបញ្ចប់ គោលបំណងទាំងនោះ ក៏អាចបង្កផលប៉ះពាល់ និងហានិភ័យត្រឡប់ទៅលើវិស័យសេដ្ឋកិច្ចវិញដែរ។ ទោះជាយ៉ាងនេះក្តី តម្លៃខូចខាតបណ្តាលមកពីការរាតត្បាត មិនបានឆ្លុះបញ្ចាំងនៅលើតម្លៃទីផ្សារទេ។ ផ្ទុយទៅវិញ ការរារាំង ការលុបបំបាត់ និងការត្រួតត្រាប្រភេទរាតត្បាត គឺក្នុងគោលបំណងផលប្រយោជន៍សេដ្ឋកិច្ចជាតិ គ្រួសារ និងសង្គម។ ដំណោះស្រាយ គួរតែបញ្ចូលគោលការណ៍ទីផ្សារដូចខាងក្រោម៖

- **អ្នកបំពុលទទួលបន្ទុកចេញថ្លៃ៖** ត្រូវផ្តល់បន្ទុកទំនួលខុសត្រូវដល់អ្នកធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជដល់សេដ្ឋកិច្ច ឬប្រព័ន្ធអេកូឡូស៊ី ចំពោះតម្លៃខូចខាតដែលបណ្តាលមកពីសកម្មភាពរបស់ពួកគេ។ កត្តាចំបង គឺអាជ្ញាធរមានសមត្ថកិច្ចនេះឯងដែលបានផ្តល់ការអនុញ្ញាតឱ្យនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត ព្រោះថាអ្នកនាំចូលប្រភេទនោះ នឹងលែងទទួលខុសត្រូវ នៅពេលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាតបានរួចផុតពីការទទួលខុសត្រូវរបស់អ្នកនាំចូល។
- **គោលការណ៍ការពារជាចម្បង៖** សក្តានុពលនៃតម្លៃខូចខាតមានទំហំធំធេង ជាពិសេសគេមិនអាចស្តារធម្មជាតិឱ្យកើតឡើងដូចដើមវិញបានទេ ហេតុនេះវាមានសារៈសំខាន់ក្នុងការគ្រប់គ្រងជាមូលដ្ឋាន ហើយគោលនយោបាយស្តីពីគោលការណ៍ការពារជាចម្បង គួរមានចែង។ គេត្រូវតែរៀបចំចាត់ចែងវិធានការណ៍ការពារជាចម្បង នៅពេលសកម្មភាពណាមួយបង្កការគំរាមកំហែងទៅដល់សុខភាពមនុស្ស ឬទៅលើបរិស្ថាន បើទោះបី គេមិនមានវិទ្យាសាស្ត្រ ដើម្បីយកមកបកស្រាយឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងរវាងហេតុ និងផល។
- **ការពារផលប្រយោជន៍សាធារណៈ៖** វាទាមទារការវិនិយោគសាធារណៈទៅលើវិធាននៃការរារាំង ការលុបបំបាត់ ការត្រួតត្រា ការបន្ធូរបន្ថយ និងការបន្សាំ ព្រោះថាការត្រួតត្រាលើប្រភេទរាតត្បាត អាចមានគ្រោះថ្នាក់ដល់ប្រយោជន៍សាធារណៈ។
- **ការលើកទឹកចិត្ត៖** ផ្តល់ការលើកទឹកចិត្តដល់ផ្នែកឯកជន ដើម្បីអូសទាញការចូលរួមគ្រប់គ្រងប្រភេទរាតត្បាត។

### ៦.៦. ការពិនិត្យ និងការតាក់តែងលិខិតបទដ្ឋានច្បាប់សមស្រប

ក្របខ័ណ្ឌច្បាប់ មានសារៈសំខាន់ចំពោះការគាំទ្រដល់កិច្ចខិតខំគ្រប់គ្រងប្រភេទរាតត្បាត ដែលបានអនុវត្តនៅកម្រិតជាតិ ប្រទេសក្នុងតំបន់ និងអន្តរជាតិ។ វិធានការណ៍ឆ្លើយតបដ៏មានប្រសិទ្ធភាព គឺអាស្រ័យទៅនឹងច្បាប់ក្នុងប្រទេស ដើម្បីរារាំង ព្រមទាំងវិធានដោះស្រាយជាក់ស្តែង។ ក្របខ័ណ្ឌច្បាប់ជាតិ គួរតែចែងឱ្យបានច្បាស់ និងគ្រប់គ្រាន់សម្រាប់កាត់បន្ថយផលប៉ះពាល់បណ្តាលមកពីប្រភេទរាតត្បាត។ ប្រការប្រឈមបំផុត គឺស្ថាប័នជាតិនានាដែលពាក់ព័ន្ធ នៅមានភាពខ្វះខាតផ្នែកថវិកា ចំណេះដឹង និងសមត្ថភាព។

### ៦.៦.១. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង

ដើម្បីឆ្លើយតបយុទ្ធសាស្ត្រខាងលើ សកម្មភាពខាងក្រោម គ្រាន់តែជាអនុសាសន៍ប៉ុណ្ណោះ៖

- ពិនិត្យឡើងវិញនូវរាល់គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងឧបករណ៍ច្បាប់ ដែលមានការពាក់ព័ន្ធដល់ប្រភេទរាតត្បាត និងកែសម្រួលឱ្យមានភាពសមស្រប និងតាមការចាំបាច់
- អនុវត្តច្បាប់ដើម្បីពង្រឹងការរារាំង ការលុបបំបាត់ និងការត្រួតត្រាលើប្រភេទរាតត្បាត
- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឧបករណ៍ច្បាប់ពាក់ព័ន្ធទៅនឹងកូតតាមអនាម័យទាំងរុក្ខជាតិ និងសត្វពាហនៈ
- រៀបចំបទដ្ឋាន ឬសៀវភៅណែនាំអំពីប្រភេទរាតត្បាត និងវិធីសាស្ត្រអនុវត្តជាក់ស្តែង
- រៀបចំសៀវភៅណែនាំអំពីកិច្ចសហការណ៍ ដើម្បីគាំទ្រដល់ដំណើរការអនុវត្តវិធីសាស្ត្រជាក់ស្តែង ដែលនឹងឈានទៅរកការកាត់បន្ថយជាអប្បរមា ឬក៏លុបបំបាត់ទាំងស្រុងនៃការនាំចូលប្រភេទរាតត្បាតដោយអចេតនា
- សហការតាមដានលើការអនុវត្តបទដ្ឋាន ឬសៀវភៅណែនាំអំពីប្រភេទរាតត្បាត និងវិធីសាស្ត្រអនុវត្តជាក់ស្តែង
- គាំទ្រអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសេចក្តីណែនាំ ប្រកាស និងវិធាននានាអំពីប្រភេទរាតត្បាតបកប្រែជាភាសាជនជាតិ បើចាំបាច់ និងធានាអនុវត្តឧបករណ៍ច្បាប់ទាំងនោះឱ្យមានប្រសិទ្ធភាព។

## ៦.៧. ការពង្រឹងកិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ និងជាមួយប្រទេសក្នុងតំបន់

ស្ថាប័នអន្តរជាតិជាច្រើនត្រូវបានបង្កើតឡើង ហើយច្បាប់ខ្លះរបស់ស្ថាប័នទាំងនោះ បានអនុម័ត និងខ្លះមិនទាន់បានទទួលការអនុម័ត ជាមួយនឹងគោលបំណងដោះស្រាយបញ្ហាប្រភេទរាតត្បាតមួយចំនួន។ ប្រការមួយរបស់អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ដែលតម្រូវឱ្យសមាជិកប្រទេសហត្ថលេខី រួមទាំងប្រទេសកម្ពុជាយើងផងដែរ គឺមាត្រាទី៨៖ "*រារាំងការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទក្រៅស្រុក ឬប្រភេទរាតត្បាត ត្រួតត្រា ឬក៏លុបបំបាត់ប្រភេទរាតត្បាតនានាដែលមានការគំរាមកំហែងដល់ប្រព័ន្ធអេកូឡូស៊ី ដែនជំរក ឬដល់ប្រភេទក្នុងស្រុក*" ។

ស្ថាប័នអន្តរជាតិមួយចំនួនទៀត មានដូចជា កម្មវិធីបរិស្ថានអន្តរជាតិ (UNEP) អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងអង្គការស្បៀង និងកសិកម្មពិភពលោក (FAO) គឺជាស្ថាប័នអន្តរជាតិដ៏សំខាន់ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួន មានដូចជា អង្គការអភិរក្សធម្មជាតិអន្តរជាតិ (IUCN) អង្គការអភិរក្សសត្វព្រៃពិភពលោក (WWF) អង្គការដីសើមពិភពលោក (Wetlands International) អង្គការអភិរក្សអន្តរជាតិ (CI) អង្គការអភិរក្សធម្មជាតិ (The Nature Conservancy) និងអង្គការCAB International ដែលមានបេសសកម្មដោះស្រាយប្រភេទរាតត្បាត និងអភិរក្សជីវៈចម្រុះ។

### ៦.៧.១. គោលការណ៍ណែនាំ

- ស្ថាប័ននានា និងកម្មវិធីគម្រោងជំនួយសម្រាប់ត្រួតត្រាប្រភេទរាតត្បាត តម្រូវឱ្យមានការប្រេបាច់បញ្ចូលបញ្ហាកង្វល់នានាទៅក្នុងវិស័យសេដ្ឋកិច្ច និងផ្លូវច្បាប់ទាំងនៅកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ
- បញ្ហាប្រភេទរាតត្បាត មានទំហំហួសពីព្រំខ័ណ្ឌសីមាប្រទេសជាតិ និងចាំបាច់ត្រូវមានអភិក្រមកម្រិតតំបន់ និងគ្រប់ជ្រុងជ្រោយសម្រាប់ដោះស្រាយបញ្ហាប្រភេទរាតត្បាត។ ហេតុនេះ គេចាំបាច់ត្រូវចែករំលែកព័ត៌មាន និងបទពិសោធន៍ រួមទាំងមេរៀនទាំងល្អ និងមេរៀនគួរជៀសវាង ព្រមទាំងភាពប្រឈម

- កិច្ចសហប្រតិបត្តិការរវាងប្រទេស គឺជាការចាំបាច់ ដើម្បីជានាលក្ខខ័ណ្ឌចាំបាច់ សម្រាប់រារាំង និងកាត់បន្ថយហានិភ័យឱ្យនៅកម្រិតអប្បរមាពីការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទរាតត្បាតដែលបង្កគ្រោះមហន្តរាយនៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ឬដែនត្រួតត្រារបស់ខ្លួនដើម្បីទប់ស្កាត់ការបំផ្លាញបរិស្ថានរបស់ប្រទេសជិតខាង
- បង្កើតបណ្តាញទំនាក់ទំនងរវាងកម្មវិធីនានាក្នុងតំបន់ និងអន្តរជាតិដែលមានការពាក់ព័ន្ធដល់ប្រភេទរាតត្បាត
- ធានាថាការចូលរួមដ៏សកម្មរបស់កម្ពុជា នៅក្នុងអនុសញ្ញានានា និងកិច្ចព្រមព្រៀងកម្រិតតំបន់ និងអន្តរជាតិ។

### ៦.៧.២. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែង

- ពង្រឹងការចូលរួមនៅក្នុងកម្មវិធីកំចាត់ប្រភេទរាតត្បាតកម្រិតតំបន់ និងពិភពលោក
- អនុវត្តកាតព្វកិច្ចនៃការគ្រប់គ្រងប្រភេទរាតត្បាតកម្រិតតំបន់ និងពិភពលោក
- លើកទឹកចិត្តលើកិច្ចសហការណ៍កម្រិតតំបន់ និងអន្តរជាតិ លើកិច្ចការរារាំង ការគ្រប់គ្រង និងការត្រួតត្រាប្រភេទរាតត្បាតដែលមាននៅក្នុងប្រទេស
- ចូលរួមអនុវត្តច្បាប់នៃភូតគាមអនាម័យជាមួយប្រទេសជិតខាង ដើម្បីសម្របសម្រួលការគ្រប់គ្រងឆ្លងកាត់ខ័ណ្ឌសីមានៃប្រភេទរាតត្បាត
- រៀបចំកិច្ចសហការណ៍រវាងវិស័យនានាជាមួយអង្គការអន្តរជាតិ ដែលមានការពាក់ព័ន្ធដល់ការធ្វើពាណិជ្ជកម្ម ទេសចរណ៍ និងគមនាគមន៍ដឹកជញ្ជូន
- កំណត់រកអត្តសញ្ញាណ និងប្រើប្រាស់ព័ត៌មានក្នុងតំបន់ដែលជាការចាំបាច់
- ជំរុញកិច្ចសហប្រិតិបត្តិការណ៍ថ្នាក់តំបន់លើការវាយតម្លៃកម្រិតហានិភ័យ ចូលរួមការរារាំង ការលុបបំបាត់ ឬការត្រួតត្រា
- ជំរុញកិច្ចសហប្រតិបត្តិការណ៍ថ្នាក់តំបន់លើការកសាងសមត្ថភាព និងចែករំលែកបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងប្រភេទរាតត្បាត។

## ៧. ក្របខ័ណ្ឌស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត

ក្រសួងបរិស្ថាន សហការណ៍ជិតស្និទ្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងបណ្តាអ្នកពាក់ព័ន្ធឯទៀតនៃស្ថាប័នរដ្ឋផ្សេងៗទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរដែនដី សង្គមស៊ីវិល គ្រឹះស្ថានអប់រំ សហគមន៍ សហគ្រឹនឯកជន និងដៃគូអភិវឌ្ឍន៍ផ្សេងៗ នឹងដើរតួនាទីដ៏សំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យទៅតាមដែនសមត្ថកិច្ច និងវិស័យរៀងៗខ្លួន ដូចមានចែងក្នុងឧបសម្ព័ន្ធ១។

### ៧.១. ស្ថាប័នជាតិ

ស្ថាប័នជាតិសំខាន់ៗ រួមមាន ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងគមនាគមន៍ និងដឹកជញ្ជូន ក្រសួងទេសចរណ៍ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គភាពរដ្ឋ និងអជ្ញាធរនានា មានតួនាទី និងភារកិច្ចដូចខាងក្រោមៈ ផ្តល់ការណែនាំ និងគាំទ្រ ទៅដល់បណ្តាញរបស់ខ្លួន ក៏ដូចជាអង្គភាពខ្លួន និងទីភ្នាក់ងារក្រោមឱវាទនៅគ្រប់កម្រិត ក្នុងគោលបំណងធានា ថាបញ្ហាប្រភេទរាតត្បាត ត្រូវបានចាត់វិធានការដោះស្រាយសមស្រប និងទាន់ពេលវេលា

- បញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព
- តាមដាន និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពនានាដែលអាចបង្ក ឬធ្វើឱ្យប៉ះពាល់បណ្តាលពីប្រភេទ រាតត្បាត
- សហការគ្នាលើការគ្រប់គ្រងប្រភេទរាតត្បាត។

### ៧.២. អាជ្ញាធរដែនដី

យោងតាមគោលនោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ការគ្រប់គ្រងបរិស្ថាន និងធនធាន ធម្មជាតិរួមទាំងប្រភេទរាតត្បាត គួរតែជាមុខព្រួញមួយនៃគោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធ មានដូចជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីជីវៈចម្រុះ និងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ។ យន្តការនានាដែលកំពុងដំណើរការនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ក្រោមជាតិ ដូចជាកម្រិតខេត្ត ស្រុក ឃុំ និងគណៈ កម្មការភូមិផងដែរ។ តាមរយៈយន្តការ និងរចនាសម្ព័ន្ធនៅមូលដ្ឋាន អាជ្ញាធរថ្នាក់ក្រោមជាតិ មានតួនាទី និងភារកិច្ច ដូចជាៈ

- សហការអនុវត្តក្នុងការដោះស្រាយបញ្ហាប្រភេទរាតត្បាតនៅក្នុងភូមិឃុំរបស់ខ្លួន
- អនុវត្តច្បាប់ សេចក្តីសម្រេច ឬសេចក្តីប្រកាសដែលមានការពាក់ព័ន្ធដល់ការគ្រប់គ្រងប្រភេទរាតត្បាត
- បញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងផែនការឃុំខេត្តសង្កាត់ និងលើកទឹកចិត្តបញ្ចូលក្នុងផែនការ-
- ចាត់ចែងកម្លាំងប្រជាសហគមន៍ដែលមានរចនាសម្ព័ន្ធស្តីពីការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ និងសង្គមស៊ីវិល ដើម្បីចូលរួមគ្រប់គ្រងប្រភេទរាតត្បាត
- កំនត់រកប្រភេទដែនជម្រកណាដែលងាយរងគ្រោះថ្នាក់ពីប្រភេទរាតត្បាតនៅក្នុងភូមិឃុំ ដើម្បីទាញការ ចាប់អារម្មណ៍ និងរៀបចំវិធានការសមស្របសម្រាប់ការគ្រប់គ្រងប្រភេទរាតត្បាត។

### ៧.៣. សហគមន៍មូលដ្ឋាន

ការបង្កើនការយល់ដឹងនៅសហគមន៍មូលដ្ឋាន គឺជាការចាប់អារម្មណ៍មួយយ៉ាងខ្លាំង។ គេក៏ត្រូវកំណត់ រកយន្តការលើកទឹកចិត្តនានាដើម្បីជំរុញការចូលរួមរបស់ប្រជាសហគមន៍ នៅមុនពេលពួកគេចូលរួមសកម្មភាព ត្រួតត្រា ឬគ្រប់គ្រងប្រភេទរាតត្បាតណាមួយ។

តួនាទីជាក់លាក់សម្រាប់ប្រជាសហគមន៍រួមមានៈ

- ការចូលរួមក្នុងដំណើរការធ្វើផែនការ ដើម្បីកំណត់រកអត្តសញ្ញាណ និងចាត់ថ្នាក់អាទិភាពនៃបញ្ហា និងសកម្មភាពដែលមានការពាក់ព័ន្ធដល់ប្រភេទរាតត្បាត

- អនុវត្តវិធានការណ៍ និងសកម្មភាពដែលបានកំណត់ថាមានអាទិភាព តាមរយៈផែនការមូលដ្ឋាន
- ចូលរួមសកម្មភាពស្តារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ
- ចូលរួមសកម្មភាពកំណត់ប្រភេទរាតត្បាតដែលមាននៅក្នុងមូលដ្ឋាន
- ចូលរួមវគ្គបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព មានដូចជាការកំណត់ប្រភេទរុក្ខជាតិ និងសត្វរាតត្បាតថ្មីៗ
- ចែករំលែកព័ត៌មានអំពីវិទ្យាសាស្ត្រនិងប្រពៃណី និងចំណេះដឹងមូលដ្ឋាន ជាមួយសហគមន៍ក្នុងមូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធឯទៀត។

ចំនុចចាប់ផ្តើមនៃការចូលរួមរបស់សហគមន៍ គឺតាមរយៈការរៀបចំផែនការគាំពារបរិស្ថានមូលដ្ឋាន។ សហគមន៍មូលដ្ឋាន អាចចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសក្នុងការកំណត់រកប្រភេទរុក្ខជាតិរាតត្បាត។ ប្រភេទរុក្ខជាតិក្រៅស្រុកដែលសង្ស័យជាប្រភេទរាតត្បាត ត្រូវរាយការជាបន្ទាន់ដល់គណៈកម្មការភូមិឃុំដែលមានស្រាប់ ឬភ្នាក់ងារមានសមត្ថកិច្ចទទួលខុសត្រូវនៅមូលដ្ឋានរបស់ខ្លួន ឬក៏រាយការមកកាន់ស្ថាប័នមានសមត្ថកិច្ចនៅខេត្ត។ ដើម្បីបំពេញសកម្មភាពទាំងនោះ គេចាំបាច់ត្រូវ៖

- បង្កើតកញ្ចប់ថវិកាដែលមានភាពងាយស្រួលយកមកប្រើប្រាស់សម្រាប់សកម្មភាពបន្ទាន់
- គាំទ្រជាប្រចាំនូវសកម្មភាពបន្ទាន់នានា
- សហការអន្តរវិស័យ
- គាំទ្រសហគមន៍ និងការចូលរួមរបស់ប្រជាសហគមន៍។

### ៧.៤. សង្គមស៊ីវិល

សង្គមស៊ីវិលដើរតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងប្រភេទរាតត្បាត។ មុខងារចំបងរបស់គេ ក្នុងចំណោមអ្នកពាក់ព័ន្ធនានា រួមមាន៖

- អនុវត្តសកម្មភាពលើការបង្កើនការយល់ដឹងអំពីប្រភេទរាតត្បាត
- ជួយពង្រឹងសមត្ថភាពសហគមន៍ដែលមានរចនាសម្ព័ន្ធចាត់តាំងហើយ និងប្រជាសហគមន៍ឱ្យចូលរួមអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនេះ
- ចងក្រងចំណេះដឹងមូលដ្ឋានរបស់ប្រជាសហគមន៍ បច្ចេកវិទ្យា និងការអនុវត្តប្រចាំថ្ងៃ អំពីការគ្រប់គ្រងប្រភេទរាតត្បាត។

### ៧.៥. វិស័យឯកជន

តួនាទីសំខាន់ៗរបស់វិស័យឯកជន ជាមួយអ្នកពាក់ព័ន្ធឯទៀត រួមមានៈ

- វិនិយោគលើវិស័យបច្ចេកវិទ្យាដែលគិតគូរបញ្ហាបរិស្ថានជាចំបង និងនិរន្តរភាព
- អនុវត្តផលប៉ះពាល់បរិស្ថានរាល់គម្រោង និងសកម្មភាពដែលប្រភេទរាតត្បាតអាចមានឥទ្ធិពលបរិស្ថានធ្ងន់ធ្ងរ
- ធានាឱ្យមានការវាយតម្លៃពីហានីភ័យជាមុនសិន មុនគិតដល់សារៈសំខាន់នៃប្រភេទក្រៅស្រុកថ្មីៗ

- ចូលរួមចំណែកធនធានថវិកា និងសម្ភារៈនានាដើម្បីគាំទ្រកម្មវិធីដែលមានទិសដៅត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត។

## ៨. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់

ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងផែនការយុទ្ធសាស្ត្រជាតិ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ គឺជាវិធីមួយដែលធានាដល់ការចូលរួមប្រើប្រាស់ធនធាននានាឱ្យមាននិរន្តរភាព សំដៅគាំទ្រដល់ការគ្រប់គ្រងប្រភេទរាតត្បាតជារៀងរហូត។ ខាងក្រោមនេះជាសកម្មភាពដែលបានស្នើឡើងដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់សំខាន់ៗនៃវិស័យមួយចំនួន៖

### ៨.១. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ

#### ៨.១.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

- សិក្សាវិភាគសេដ្ឋកិច្ច និងអេកូឡូស៊ីនៃទំនាក់ទំនងរវាងប្រភេទរាតត្បាតទៅនឹងការអភិវឌ្ឍន៍ជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រភេទរាតត្បាតទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ផ្ដល់ការគណនាឱ្យបានច្បាស់អំពីតម្លៃសរុបនៃការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត ធ្វើយ៉ាងណាឱ្យអ្នកនយោបាយមានភាពពេញចិត្ត និងទំនុកចិត្ត ដើម្បីលើកកម្ពស់ការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីប្រភេទរាតត្បាតនេះ។

#### ៨.១.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម

ការដាក់បញ្ចូលសកម្មភាពនៃការគ្រប់គ្រងប្រភេទរាតត្បាត ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម អាចជាឱកាសមួយសម្រាប់គាំទ្រ និងពង្រឹងការងារពាក់ព័ន្ធវិស័យកសិកម្ម ជាពិសេសទប់ស្កាត់ រារាំង និងគ្រប់គ្រងហានិភ័យនៃប្រភេទរាតត្បាត ទៅលើផលិតភាព និងទិន្នផលនៃផលិតផលកសិកម្ម។

#### ៨.១.៣. យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ

- បញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ
- ជម្រុញការដាក់បញ្ចូលបញ្ហាប្រភេទរាតត្បាតទៅក្នុងផែនការសកម្មភាពដែលគាំពារបរិស្ថានថ្នាក់មូលដ្ឋាន។

#### ៨.១.៤. យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីជីវៈចម្រុះ

ប្រទេសកម្ពុជាមានយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីជីវៈចម្រុះ ទើបបានផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ និងរៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ។ គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ មានសមាជិកតំណាងក្រសួងសំខាន់ៗ និងអភិបាលខេត្តមួយចំនួន ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច និងវិស័យរបស់ខ្លួន។ ការអនុម័តយល់ព្រមទៅលើយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីជីវៈចម្រុះ មានអត្ថន័យធំធេងក្នុងការលើកកម្ពស់មុខមាត់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ។

គោលបំណងទូទៅរបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីជីវៈចម្រុះ រួមមាន៖

- ថែរក្សាធនធានជីវៈចម្រុះ និងផលិតភាពនៃប្រព័ន្ធអេកូឡូស៊ី តាមរយៈកិច្ចការពារប្រភេទមានតម្លៃនៃសរីរាង្គមានជីវិតនានាដែលមាននៅក្នុងធម្មជាតិ និងបរិស្ថានកែច្នៃ ជាពិសេស ព្រៃឈើ ទឹក និងសមុទ្រ ដីសើម និងដីកសិកម្ម
- គ្រប់គ្រងសកម្មភាពមនុស្ស និងការប្រើប្រាស់ធនធានជីវៈចម្រុះ ដើម្បីធានាដល់ការថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះដែលមានសារៈសំខាន់ចំពោះជីវភាពរស់នៅ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម
- ធានាផលប្រយោជន៍ដែលកើតចេញពីការប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយនិរន្តរភាព ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

### ៨.២. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងគោលនយោបាយជាតិ

ជម្រុញការដាក់បញ្ចូលបញ្ហាប្រភេទរាតត្បាតទៅក្នុងគោលនយោបាយ នៅពេលណាមានការពិនិត្យសើរើឡើងវិញ ដើម្បីធានានូវប្រសិទ្ធភាព និងបំពេញបន្ថែមទៅនឹងតម្រូវការប្រទេសជាតិ។ បញ្ហាសំខាន់ៗដែលមានការពាក់ព័ន្ធ មានចែងនៅក្នុងយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ នៅគ្រប់វិស័យអន្តរាគមន៍។

### ៨.៣. ការបញ្ជ្រាបបញ្ហាប្រភេទរាតត្បាតទៅក្នុងក្របខ័ណ្ឌច្បាប់

- គាំទ្រអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងរៀបចំសេចក្តីជូនដំណឹង ប្រកាស និងឯកសារផ្លូវច្បាប់នានាដែលពាក់ព័ន្ធនឹងប្រភេទរាតត្បាត
- បកប្រែទៅជាភាសាជាតិ ឬភាសាជនជាតិ និងធ្វើឱ្យមានភាពងាយយល់ និងអាចអនុវត្តទៅបាននូវសេចក្តីជូនដំណឹងប្រកាស និងឯកសារផ្លូវច្បាប់នានា អំពីប្រភេទរាតត្បាតដែលមានការពាក់ព័ន្ធ
- គាំទ្រដល់ដំណើរការអនុវត្តច្បាប់តាមរយៈការរៀបចំសៀវភៅណែនាំអំពីការអនុវត្តច្បាប់។

## ៩. ប្រភពធនធានហិរញ្ញវត្ថុ

### ៩.១. រដ្ឋាភិបាល

ដោយសារថវិការដ្ឋនៅមានកម្រិតកំណត់ រដ្ឋាភិបាល ប្រហែលមិនមានភាពងាយស្រួលក្នុងការវិភាជន៍កញ្ចប់ថវិកាសម្រាប់ការរារាំង ការត្រួតត្រា ឬការគ្រប់គ្រង ដ៏រាបណាសកម្មភាពទាំងនោះមានភាពច្បាស់លាស់សមហេតុផល និងសមស្រប។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាល មានកាតព្វកិច្ចអនុវត្តមាត្រាទី៨(h) របស់អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ហើយមាត្រាទី២០របស់អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ក៏បានតម្រូវឱ្យប្រទេសហត្ថលេខី *"ផ្តល់ទៅតាមសមត្ថភាព និងលទ្ធភាពថវិកាគាំទ្រ និងលើកទឹកចិត្តទៅលើសកម្មភាពនៅក្នុងប្រទេសខ្លួន ដែលមានចេតនាសម្រេចឱ្យបាននូវគោលបំណងនានារបស់អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះដោយស្របទៅតាមផែនការជាតិ អាទិភាពជាតិ និងកម្មវិធីនានា"*។

ហេតុនេះ រដ្ឋាភិបាល ត្រូវតែប្តេជ្ញាចិត្តបំពេញកាតព្វកិច្ចខាងលើឱ្យខាងតែបាន ដោយបង្កើនកញ្ចប់វិភាជន៍ថវិកា សម្រាប់គាំទ្រកម្មវិធីអភិរក្ស និងគាំពារបរិស្ថាន រួមទាំងការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត។ ដើម្បីរៀបចំថវិកាបដិភាគឱ្យបានគ្រប់គ្រាន់ រាល់កិច្ចខិតខំប្រឹងប្រែងណាមួយ ត្រូវតែបញ្ចូលយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនូវរាល់ឱកាសផ្តល់ជូនទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនានា

ផងដែរ រួមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ផែនការវិនិយោគតាមវិស័យនានា និងផែនការវិនិយោគឃុំសង្កាត់។

**៩.២. ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ**

ការធ្វើឱ្យមាន និងការនាំចូលប្រភេទរាតត្បាត គឺជាបញ្ហាជាតិ និងក៏ជាបញ្ហាសកលដែរ។ ប្រភេទរាតត្បាតមិនត្រឹមតែចាំបាច់ឱ្យមានអន្តរាគមន៍កម្រិតជាតិ តែសកម្មភាពរបស់ប្រទេសមួយ អាចបង្កការរាលដាលដល់ប្រទេសជិតខាង និងសហគមន៍អន្តរជាតិ។ ជានិច្ចកាល ប្រទេសមួយ មិនមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រងចំណាយលើការត្រួតត្រាប្រភេទរាតត្បាត ដរាបណាប្រទេសនានា រួមទាំងដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារហិរញ្ញវត្ថុអន្តរជាតិ ត្រូវផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែម។ ទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ទ្វេភាគី ឬ/និង ពហុភាគី គួរតែត្រូវបានលើកទឹកចិត្តដូចខាងក្រោមដើម្បី៖

- គាំទ្រសកម្មភាពដែលមានការពាក់ព័ន្ធដល់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត
- គាំទ្រអភិក្រមនៃកិច្ចសហការណ៍ល្អកម្រិតជាតិ លើការពង្រឹងសមត្ថភាពក្នុងន័យសហប្រតិបត្តិការណ៍អន្តរជាតិ
- លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការណ៍កម្រិតតំបន់នៅក្នុងកម្មវិធីដែលបានគាំទ្រថវិកា
- ពិនិត្យឡើងវិញនូវដំណើរការធ្វើផែនការជាតិ និងយុទ្ធសាស្ត្រជាតិដោយធានាថាកម្មវិធីគាំទ្រពីដៃគូអភិវឌ្ឍន៍ នឹងមិនមានការធ្វើឱ្យមាន ឬការនាំចូលប្រភេទរាតត្បាតដោយចេតនា និងកាត់បន្ថយការធ្វើឱ្យមាន ឬការនាំចូលប្រភេទរាតត្បាតដោយចេតនាឱ្យនៅត្រឹមកម្រិតអប្បរមា។

**៩.៣. វិស័យឯកជន**

កជន អាចចូលរួមវិភាគទានធនធានរបស់ពួកគេមានមធ្យោបាយជាច្រើនដែលវិស័យឯសម្រាប់រារាំង ត្រួតត្រា ឬគ្រប់គ្រងប្រភេទរាតត្បាត តាមរយៈសកម្មភាពដូចខាងក្រោម៖

- វិនិយោគលើវិស័យបច្ចេកវិទ្យាដែលគិតគូរបញ្ហាបរិស្ថានជាចម្បង និងនិរន្តរភាព
- ចូលរួមវិភាគទានដើម្បីគាំទ្រកម្មវិធីនានាដែលសំដៅត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាតដែលជាផ្នែកមួយនៃការទទួលខុសត្រូវរបស់ពួកគេក្នុងការធ្វើធុរកិច្ច។

វិស័យឯកជន ក៏គួរលើកទឹកចិត្តឱ្យវិនិយោគលើគម្រោងសកម្មភាពនានាដែលរារាំងជាអប្បបរមានៃការធ្វើឱ្យកើតមាន ឬការនាំចូលប្រភេទរាតត្បាត។

## ១០. ការតាមដាន និងការវាយតម្លៃ

ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត តម្រូវឱ្យមានការតាមដាន និងវាយតម្លៃជាប្រចាំទៅលើដំណើរការទាំងនោះ។ ក្រុមការងារបច្ចេកទេសគ្រប់គ្រងជីវៈចម្រុះ មានភារកិច្ចទទួលខុសត្រូវលើកិច្ចសហការរាល់សកម្មភាពអនុវត្តក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនៅកម្រិតជាតិ។ ស្ថាប័នមានសមត្ថកិច្ច មានភារកិច្ចទទួលខុសត្រូវលើការតាមដាន និងអនុវត្តភារកិច្ចរៀងៗខ្លួន។ ដើម្បីមានលទ្ធភាពតាមដានយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតឱ្យមានប្រសិទ្ធភាព ក្រុមការងារ

បច្ចេកទេសគ្រប់គ្រងជីវៈចម្រុះ និងស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ ដោយសហការណ៍ជាមួយគ្រឹះស្ថានអប់រំ អនុវត្តភារកិច្ចដូចខាងក្រោម៖

- ដឹកនាំការរៀបចំផែនការតាមដាន និងវាយតម្លៃ ដោយដាក់បញ្ចូលទម្រង់នៃរចនាសម្ព័ន្ធដែលត្រូវរាយការណ៍ សូចនាករនៃការបំពេញការងារ និងផលប៉ះពាល់ សូចនាករដែលត្រូវសម្រេច និងឧបករណ៍តាមដាន
- ជួយស្ថាប័នឯទៀតដើម្បីរៀបចំផែនការតាមដានរបស់ស្ថាប័នសាមី និងស្វែងរកលទ្ធភាពបញ្ជ្រាបផែនការយុទ្ធសាស្ត្រជាតិទាំងនោះទៅក្នុងផែនការតាមដានប្រភេទរាតត្បាតទាំងមូល
- ជួយស្ថាប័នឯទៀត ដើម្បីរៀបចំសូចនាករអនុវត្តផ្អែកលើទិន្នន័យមូលដ្ឋានជាមួយនឹងលទ្ធផលតាមជំហ៊ាននៃការរីកចម្រើនក្នុងរយៈពេល៥ឆ្នាំ និងរយៈពេលរំកិលណាមួយជាក់លាក់។

**ឧបករណ៍តាមដានសំខាន់ៗរួមមាន៖**

- របាយការណ៍ប្រចាំឆ្នាំរបស់អ្នកពាក់ព័ន្ធ
- របាយការណ៍ប្រចាំឆ្នាំរបស់អង្គប្រជុំគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ ដែលបានពិភាក្សាពីវឌ្ឍនភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត
- របាយការណ៍ជាតិដែលបានរៀបចំដើម្បីរាយការណ៍ជូនអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ។

បច្ចុប្បន្ន គម្រោងការបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទរាតត្បាតចង្រៃលើកិច្ចការពារអភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍នៅកម្ពុជា បានផ្តល់ថវិកាមួយចំនួនដើម្បីផ្តួចផ្តើមអនុវត្តសកម្មភាពណាដែលបន្ទាន់ ហើយនឹងមានចែងនៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតនូវចំនុចមួយចំនួនដូចខាងក្រោម៖

- កសាងសមត្ថភាពលើការរារាំង ការគ្រប់គ្រង ឬការត្រួតត្រាប្រភេទរាតត្បាត
- រៀបចំបង្កើតឧបករណ៍ និងស្រាវជ្រាវរកវិធីសាស្ត្រសម្រាប់ការរារាំង ការកំណត់រកសញ្ញា និងការឆ្លើយតបជាបន្ទាន់ទៅនឹងការរាតត្បាត ការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត និងការស្តារឡើងវិញនៅទីតាំងដែលបានខូចខាតដោយសារប្រភេទរាតត្បាត
- កំណត់យកការស្រាវជ្រាវជាបញ្ហាអាទិភាពទៅលើប្រភេទរាតត្បាត
- គ្រប់គ្រង និងចែករំលែកព័ត៌មាន
- អប់រំ និងបង្កើនការយល់ដឹងសាធារណៈ
- ពិនិត្យឡើងវិញនូវគោលនយោបាយ ផែនការ និងផ្លូវច្បាប់នានា។

# សន្និដ្ឋាន និងអនុសាសន៍

សរុបសេចក្តីមក វាមានសារៈសំខាន់ណាស់ក្នុងការយកចិត្តទុកដាក់ដល់ការបង្កើតសេចក្តីណែនាំអំពីគោលនយោបាយ និង យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត ដែលនឹងផ្តល់ឱកាសសម្រាប់ប្រទេសកម្ពុជាយើង អាចពិនិត្យពិច័យថាតើប្រភេទរាតត្បាតណាខ្លះមានវត្តមាននៅក្នុងប្រទេស ហើយប្រភេទរាតត្បាតណាមួយ ត្រូវបានកំណត់ថាជាប្រភេទអាទិភាពសម្រាប់ធ្វើការត្រួតត្រានិងគ្រប់គ្រង ហើយថាតើយន្តការណាមួយដែលត្រូវបង្កើតដើម្បី ដើម្បីទប់ស្កាត់ប្រភេទរាតត្បាតទាំងនោះក្នុងរយៈពេលយូរអង្វែង។ ការកំណត់យកបញ្ហារបស់ព្រះខ្លបយក្ស ឬបន្លាអួយយ៉ាស់នៅកម្ពុជា ធ្វើជាករណីសិក្សា និងអនុវត្តបង្ហាញតាមរយៈ*គម្រោងការបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទរាតត្បាតលើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើ ក្នុងតំបន់អាស៊ីអាគ្នេយ៍* បានរកឃើញជាក់ច្បាស់ថាប្រភេទរាតត្បាតនេះ បានបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងសម្បើមដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់កម្ពុជា ជាពិសេសប៉ះពាល់ដល់វិស័យកសិកម្ម វារីវប្បកម្ម និងរបរចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍មូលដ្ឋាន។

ប្រភេទរាតត្បាត មិនត្រឹមតែបង្កការគម្រាមកំហែង ឬបង្កផលប៉ះពាល់អវិជ្ជមានដល់ប្រទេសកម្ពុជាតែប៉ុណ្ណោះទេ តែវាបានកំពុងបង្កហានិភ័យដល់ប្រទេសជាច្រើនក្នុងតំបន់ និងពិភពលោក។ រៀងរាល់ថ្ងៃ ប្រភេទក្នុងស្រុក និងទីជម្រករបស់វា កំពុងប្រឈមនឹងហានិភ័យនៃការបាត់បង់ជាបណ្តើរៗ ដោយសារវត្តមានប្រភេទក្រៅស្រុក រួមទាំងរុក្ខជាតិ និងសត្វ។ ការរាតត្បាតរបស់ប្រភេទក្រៅស្រុកទាំងនេះ បានកំពុងកើនឡើង ដោយសារការធ្វើចរាចរបែបអនាធិបតេយ្យនៅលើទីផ្សារ និងការប្រើប្រាស់ប្រភេទក្រៅស្រុក និងផ្លូវចម្លងនានា ក្នុងបរិការនៃសកម្មភាពដ៏ទូលំទូលាយ។ ហេតុនេះ គេចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំង និងត្រួតត្រាប្រភេទរាតត្បាតទាំងនោះមិនឱ្យរីករាលដាលបន្ត។

អនុសាសន៍ចែងនៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាត គ្រាន់តែជាជំហ៊ាននៃកិច្ចផ្តួចផ្តើម ក្នុងការដោះស្រាយបញ្ហាប្រភេទរាតត្បាតដែលកើតមានទូទាំងប្រទេសរួចទៅហើយនោះ។ អនុសាសន៍ទាំងនោះ ចាំបាច់ត្រូវតែកែលំអជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពនៃប្រភេទរាតត្បាតនៅក្នុងប្រទេស និងឈានទៅរកការគ្រប់គ្រងទូទាំងប្រទេស។

ការអនុវត្តគោលការណ៍ណែនាំមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនេះ នឹងអាចធ្វើទៅបានដ៏រាបណា រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ពីសារៈសំខាន់នៃការរារាំង ឬការត្រួតត្រាលើការរីករាលដាលនៃប្រភេទរាតត្បាតនៅទូទាំងប្រទេស។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែប្តេជ្ញាចិត្តក្នុងការផ្តល់ថវិកា និងកៀគរថវិកាសម្រាប់អនុវត្តកម្មវិធីគ្រប់គ្រងប្រភេទរាតត្បាតឱ្យមានជានិរន្តន៍តទៅ និងស្វែងរកជំរើសនានាធ្វើការឆ្លើយតបណាមួយ។ ការកំណត់ទំហំនៃសេចក្តីត្រូវការថវិកាណាមួយ គួរតែមានការវាយតម្លៃទៅលើហានិភ័យនៃការផ្ទុះឡើងពីការរាតត្បាត និងពីវិសាលភាពដែលអាចផ្ទុះឡើង។ រដ្ឋាភិបាល ក៏គួរតែគាំទ្រដល់ការបង្កើតហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីក្រសួង មន្ទីរ ឬភ្នាក់ងាររដ្ឋនានា អាចអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រភេទរាតត្បាតប្រកបដោយប្រសិទ្ធភាព និងជោគជ័យ។

ការទទួលខុសត្រូវលើការរារាំង ការគ្រប់គ្រង និងការត្រួតត្រាប្រភេទរាតត្បាត មិនគួរដាក់បន្ទុកលើរដ្ឋាភិបាលទាំងស្រុងនោះឡើយ។ បណ្តាដៃគូពាក់ព័ន្ធនានា ក៏ត្រូវតែចូលរួមចែករំលែកការទទួលខុសត្រូវផងដែរ។ គេបានផ្តល់អនុសាសន៍ថា នៅពេលរដ្ឋាភិបាលផ្តល់ការអនុម័តគោលការណែនាំគោលនយោបាយ ចំណែកស្ថាប័ន និង

អង្គការចាត់តាំងពាក់ព័ន្ធនានា គួរតែបង្ហាញការប្តេជ្ញាចិត្តក្នុងការកាត់បន្ថយការបាត់បង់ជីវៈចម្រុះ ដោយសារឥទ្ធិពលបំផ្លាញរបស់ប្រភេទក្រៅស្រុក។ វិធីមួយដើម្បីនាំស្ថាប័ន និងអង្គការចាត់តាំងពាក់ព័ន្ធនានា ចូលរួមការអនុវត្តគឺត្រូវផ្តល់ការគាំទ្រអនុម័តដោយស្ម័គ្រចិត្ត នូវរបៀបរបបនៃការអនុវត្តប្រហាក់ប្រហែលទៅនឹងអ្វី ដែលមានចែងក្នុងឧបសម្ព័ន្ធ២។ របៀបរបបនៃការអនុវត្តទាំងនោះ គួរតែបានដាក់តាំងបង្ហាញយ៉ាងទូលំទូលាយនៅគ្រប់ទីកន្លែងសាធារណៈ ដូចជាសួនច្បារ សួនផ្កា ថ្នាលបណ្តុះកូនឈើ ថ្នាលលក់ផ្កា កសិដ្ឋាន សួនសត្វ កសិដ្ឋានវារីវប្បកម្ម ជាដើម។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ សកម្មភាពអាទិភាពសម្រាប់គ្រប់គ្រងប្រភេទរាតត្បាត

| ល.រ. | សកម្មភាពអាទិភាព | កំរិតអាទិភាព | ស្ថាប័នសំខាន់ៗ |
|---|---|---|---|
| ១ | រៀបចំធ្វើសារពើភ័ណ្ឌប្រភេទរាតត្បាតក្នុងស្រុក | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ២ | សិក្សាវាយតម្លៃពីហានីភ័យនៃប្រភេទរាតត្បាត ដែលមានវត្តមាន និងប្រភេទក្រៅស្រុក | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៣ | សិក្សា និងពិនិត្យឡើងវិញរាល់គោលនយោបាយ និងច្បាប់លិខិតបទដ្ឋានដែលមានស្រាប់ និងស្ថាប័ននានាដែលកំពុងដំណើរការ | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៤ | ពង្រឹងភូតគាមអនាម័យ និងការត្រួតពិនិត្យប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៥ | រៀបចំចងក្រងមូលដ្ឋានទិន្នន័យ និងព័ត៌មានស្តីពីប្រភេទរាតត្បាតកំរិតជាតិ និងផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៦ | កំណត់ប្រភេទរាតត្បាត និងតំបន់អាទិភាពក្នុងគោលដៅគ្រប់គ្រង និងលុបបំបាត់ប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៧ | បញ្ជ្រាបចំណេះដឹងទូទៅដល់អ្នកពាក់ព័ន្ធអំពីហានីភ័យខ្ពស់ការគ្រប់គ្រងនិងលុបបំបាត់ប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៨ | បង្កើត និងអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មាន (Clearing house mechanism) | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ៩ | លើកកំពស់ការស្តារប្រភេទក្នុងស្រុកឡើងវិញ (សត្វ និងរុក្ខជាតិ) | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១០ | សិក្សាពីសក្តានុពលនៃវត្តមានសត្រូវធម្មជាតិដើម្បីត្រួតត្រាប្រភេទរាតត្បាតអាទិភាព | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១១ | សិក្សាពីលទ្ធភាពលើការប្រើភ្នាក់ងារសរីរាង្គរស់ត្រួតត្រាជីវសាស្ត្រ (bio-control) | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១២ | សិក្សាវាយតម្លៃលក្ខណៈជីវសាស្ត្រ និងការប្រើប្រាស់រុក្ខជាតិដើម្បីទប់ស្កាត់រាតត្បាតរបស់រុក្ខជាតិរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១៣ | សហការជាមួយដៃគូក្នុងការគ្រប់គ្រង បង្កា រារាំង និងលុបបំបាត់ប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១៤ | កសាងសមត្ថភាពជំនាញដល់អ្នកពាក់ព័ន្ធអំពីការកំណត់អត្តសញ្ញាណប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១៥ | បង្កើតប្រព័ន្ធវាយតម្លៃ និងតាមដានប្រភេទរាតត្បាតជាប្រចាំ | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១៦ | ពង្រឹងការអនុវត្តច្បាប់ស្តីពីជីវៈចម្រុះ និងជីវសុវត្ថិភាព | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | | | ផ្សេងៗទៀត |
| ១៧ | ផ្សព្វផ្សាយសាធារណអំពីវត្តមានប្រភេទរាតត្បាតចូលថ្មីដល់សាធារណជនជាបន្ទាន់ | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១៨ | រៀបចំសាកល្បងអនុវត្តវិធីសាស្ត្រគ្រប់គ្រង និងលុបបំបាត់ប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ១៩ | ផ្សព្វផ្សាយវិធីសាស្ត្រ បទពិសោធន៍ និងលទ្ធផលការងារគ្រប់គ្រងប្រភេទរាតត្បាត | ខ្ពស់ | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ២០ | ពង្រឹង និងកែលម្អជាប្រចាំប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមានស្រាប់ | មធ្យម | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ២១ | បច្ចុប្បន្នភាពចំណេះដឹងមូលដ្ឋាននិងវិធីសាស្ត្រគ្រប់គ្រងនិងលុបបំបាត់ប្រភេទរាតត្បាត | មធ្យម | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |
| ២២ | បង្កើតប្រព័ន្ធព្យាករណ៍ថ្នាក់ជាតិ និងបង្កើតយន្តការឆ្លើយតបរហ័សអំពីប្រភេទរាតត្បាត | មធ្យម | ក្រសួង ក្រកសក និងក្រជទឧ |
| ២៣ | ពង្រឹងកែលម្អលទ្ធភាពយកមកប្រើប្រាស់នូវសរីរាង្គណាមួយដែលគេត្រូវការ ដោយយកចេញពីប្រភេទរុក្ខជាតិក្នុងស្រុកដែលមានភាពបន្សាំខ្ពស់ | ទាប | ក្រសួង ក្រកសក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត |

**ឧបសម្ព័ន្ធ២៖ និតិវិធីជាគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការណ៍របស់ស្ថានប័នពាក់ព័ន្ធនានា**

- ស្ថាប័ន ឬបុគ្គល មិនត្រូវចែកចាយពូជ ប្រភេទរុក្ខជាតិ ឬសត្វ ដែលបានស្គាល់ថាជាប្រភេទរាតត្បាត លើកលែងតែក្នុងគោលបំណងបំរើការសិក្សាស្រាវជ្រាវ និងមានការអនុញ្ញាត
- ផ្តល់ព័ត៌មានតាមរយៈការរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចដែលនៅជិតបំផុត នៅពេលឃើញវត្តមានប្រភេទរាតត្បាត
- ព្យាយាមរកព័ត៌មានអំពីប្រភេទរាតត្បាតនៅក្នុងភូមិសាស្ត្រ និងដែនដីរបស់ខ្លួន ដូចជាពីអ្នកបង្កាត់ពូជ កន្លែងបង្កាត់ពូជ សួនច្បារដំណាំ កសិដ្ឋាន ថ្នាលបណ្តុះកូនឈើ ឬថ្នាលចិញ្ចឹមសត្វ ។ល។ ក្រុមអភិរក្ស និងភ្នាក់ងារផ្សព្វផ្សាយ
- ធានាថាប្រភេទក្រៅស្រុក ឬប្រភេទនាំចូល ដែលបាននាំចូលក្នុងគោលបំណងអ្វីមួយ ត្រូវប្រកាសប្រាប់ដល់ ភ្នាក់ងារនៅតាមច្រកចេញចូលឆ្លងកាត់ប្រទេស និងព្រលានយន្តហោះ
- ពិនិត្យ និងអនុវត្តវិធានល្អៗនានាដែលបានណែនាំយកមកអនុវត្តចំពោះការត្រួតត្រា និងការគ្រប់គ្រងប្រភេទរាតត្បាត
- អប់រំផ្សព្វផ្សាយដល់សហគមន៍ រួមទាំង អ្នកបង្កាត់ពូជ កន្លែងបង្កាត់ពូជ សួនច្បារដំណាំ កសិដ្ឋាន ថ្នាល បណ្តុះកូនឈើ ឬថ្នាលចិញ្ចឹមសត្វ ។ល។ ក្រុមអភិរក្ស និងភ្នាក់ងារផ្សព្វផ្សាយដែលមាននៅក្នុងតំបន់របស់ខ្លួនអំពីប្រភេទរាតត្បាតតាមរយៈមធ្យោបាយ និងវិធីសាស្ត្រសមស្រប
- កំចាត់ចោលគ្រប់ប្រភេទរាតត្បាតចេញពីភូមិសាស្ត្រ និងដែនដីរបស់ខ្លួន ដោយជំនួសមកវិញនូវប្រភេទណាមិនរាតត្បាត និងប្រភេទក្នុងស្រុក
- ស្នើសុំប្រព័ន្ធផ្សព្វផ្សាយនានាជួយឃោសនាផ្សព្វផ្សាយអំពីបញ្ហាបង្កឡើងដោយប្រភេទរាតត្បាតដល់សាធារណជន
- សិក្សា និងស្វែងយល់រាល់បណ្តាបទដ្ឋានច្បាប់ គោលការណ៍ណែនាំ និងប្រកាសដើម្បីរារាំង បង្កាត្រួតត្រា និងគ្រប់គ្រងប្រភេទរាតត្បាត
- ស្វែងរកដៃគូជាមួយស្ថាប័ន អង្គការ និងសមាគមន៍នានាក្នុងការគ្រប់គ្រងប្រភេទរាតត្បាតដែលមានហានីភ័យខ្ពស់
- ចូលរួមវិភាគទាន និងបរិចាកធនធាននានា ព្រមទាំងចូលរួមអនុវត្តសកម្មភាពផ្សេងៗដើម្បីគ្រប់គ្រងប្រភេទរាតត្បាត
- ចូលរួមដាំស្តារ និងចិញ្ចឹមតែប្រភេទដែលមានសុវត្ថិភាព និងគាំពារបរិស្ថាននៅក្នុងសួន និងកសិដ្ឋាន។

ឧបសម្ព័ន្ធ៣៖ ក្របខ័ណ្ឌគោលនយោបាយ និងការគ្រប់គ្រងប្រភេទរាតត្បាត

**ស្ថាប័នសម្របសម្រួលនិងដឹកនាំ**

- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

**វិសាលភាព**

- រុក្ខជាតិដីគោក និងក្នុងទឹក
- សត្វរស់លើគោក និងក្នុងទឹក

## គោលដៅជាយុទ្ធសាស្ត្រ

**ការរារាំង**

ការនាំចូលប្រភេទក្រៅស្រុកមានគ្រោះថ្នាក់ដោយប្រយោល និងដោយផ្ទាល់

**ការផ្តល់សញ្ញាបន្ទាន់**

-ការកំណត់ប្រភេទរាតត្បាតមុនឆ្លងដែនចូលក្នុងប្រទេស

-អន្តរាគមន៍ឆ្លើយតបភ្លាមៗនៅពេលចូលដល់ក្នុងប្រទេស

**ការគ្រប់គ្រង**

នៅពេលប្រភេទរាតត្បាតបានមានវត្តមានរួចហើយ និងកំពុងរីករាលដាល

**ការស្តារឡើងវិញ**

ស្តារទីតាំងដែលទទួលរងការគំរាមកំហែង និងរិចរិល

## យុទ្ធសាស្ត្រអនុវត្ត

**ការវាយតម្លៃ**

-កំណត់អត្តសញ្ញាណ

-ការវាយតម្លៃ

-ការគ្រប់គ្រង

-ទំនាក់ទំនងផ្សព្វផ្សាយ

**ការសិក្សា**

-កិច្ចអន្តរាគមន៍

-ការកំណត់ឈ្មោះ

-ការសិក្សាពីវិធីត្រួតត្រា

-ការតាមដាន

-ការសិក្សាវាយតម្លៃ

**នីតិកម្មច្បាប់**

-ការពង្រឹងក្របខ័ណ្ឌច្បាប់

-ការពង្រឹងលើការអនុវត្តច្បាប់

**ការចូលរួម**

-បង្កើនចំណេះដឹងនិងព័ត៌មាន

-ការអប់រំ ផ្សព្វផ្សាយ

-ការពង្រឹងសិទ្ធគ្រប់គ្រង

**កិច្ចសហការ**

- ទ្វេភាគី
- កំរិតតំបន់
- ពហុភាគី

ឧបសម្ព័ន្ធ៤៖ បញ្ជីឈ្មោះនៃប្រភេទរាតត្បាតអាទិភាពនៅកម្ពុជាដែលត្រូវមានវិធានការកំចាត់

| លរ | ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | *ឈ្មោះវិទ្យាសាស្ត្រ* | ប្រទេសឬទ្វីបកំណើតដើម |
|---|---|---|---|---|
| **ក) រុក្ខជាតិ** | | | | |
| ១ | ព្រះខ្លបយក្ស (បន្លាអួយយ៉ាស់) | Giant mimosa / Catclaw mimosa | *Mimosa pigra* | ទ្វីបអាមេរិកឡាទិន |
| ២ | ព្រះខ្លបដំរី | Giant Sensitive Mimosa | *Mimosa diplotricha* | ទ្វីបអាមេរិកកណ្តាល ខាងត្បូងប្រទេសប្រេស៊ីល និងតំបន់ការ៉េបៀន (Caribbean) |
| ៣ | ទន្ទ្រានខេត្ត | Siam Weed | *Chromolaena odorata* | ទ្វីបអាមេរិកកណ្តាល និងខាងត្បូងពីម៉ិចស៊ិកូ និងតំបន់ការ៉េបៀន (Caribbean)ដល់ប្រទេសប្រេស៊ីល |
| ៤ | កំប្លោក | Water hyacinth | *Eichhornia crassipes* | អាងទន្លេអាម៉ាហ្សូន |
| ៥ | វល្លិ៍ទន្ទ្រានខេត្ត | Mile-a-minute weed | *Mikania micrantha* | ទ្វីបអាមេរិក(ខាងត្បូងកណ្តាល) |
| ៦ | ព្រះខ្លបសំពះ(តូចឬវារ) | Sensitive Mimosa / Touch-Me-Not | *Mimosa pudica* | អាមេរិកឡាទិនខាងត្បូង និងអាមេរិកឡានទិនកណ្តាល |
| ៧ | ផ្កាចិញ្ចៀន | Lantana | *Lantana camara* | អាមេរិកឡានទិនខាងត្បូង និងកណ្តាល និងអាមេរិកខាងត្បូង |
| ៨ | ល្ហុងខ្វង | Purging Nut | *Jatropha curcas* | តំបន់ត្រូពិកនៃសហរដ្ឋអាមេរិក និងតំបន់ការ៉េបៀន |
| ៩ | ស្មៅបារាំង | Para grass | *Brachiaria mutica* | ទ្វីបអាហ្វ្រិក |
| ១០ | ដង្ហិត | Candlebush / Ringworm cassia | *Cassia alata* | ព្រៃត្រូពិកនៃទ្វីបអាមេរិកឡាទិន |
| ១១ | ស្មៅប្រម៉ោយ (ត្រែង) | Arundo grass | *Arundo donax* | ទ្វីបមេឌីទែរានេ |
| ១២ | ស្មៅកន្ទុយឆ្កែ | Mission Grass | *Pennisetum polystachion* | ព្រៃត្រូពិកនៃទ្វីបអាហ្វ្រិក |
| ១៣ | ដំរី | Peruvian Primrose | *Ludwigia peruviana* | ទ្វីបអាមេរិកឡាទិន |
| **ខ) ត្រី** | | | | |
| ១ | ត្រីចាបទឹកសាប | Red-bellied Pacu | *Piaracus brachypomus* | អាម៉ាហ្សូន |
| ២ | ត្រីទីឡាព្យា | Blue Tilapia | *Oreochromis aureus* | អាហ្វ្រិក និងអាស៊ីកណ្តាល |

| | | | | |
|---|---|---|---|---|
| ៣ | ត្រីទីឡាព្យាខ្មៅ | Mozabique Tilapia ឬ Java Tilapia | *Oreochromis mossambicus* | អាហ្វ្រិកខាងត្បូង |
| ៤ | ត្រីទីឡាព្យា | | *Tilapia nilotica* | អាហ្វ្រិកដល់អេហ្ស៊ីប |
| ៥ | ត្រីកាប | Mrigal carp | *Cirrhinus mrigala* | ប្រទេសឥណ្ឌា |
| ៦ | ត្រីទីឡាព្យា | Red tilapia | *Oreochromis x O. Mossambicus* | អាហ្វ្រិកខាងត្បូង |
| ៧ | ត្រីទីឡាព្យាឆ្នូត | Nile Tilapia | *Oreochromis  niloticus* | ទ្វីបអាហ្វ្រិក |
| ៨ | ត្រីកាបស៊ីស្មៅ | Grass Carp | *Ctenopharyngodon idella* | អាស៊ីខាងកើត |
| ៩ | ត្រីកាបស | Silver Carp | *Hypophthalmichthys molitrix* | ចិន និងស៊ីបេរីខាងកើត |
| ១០ | (ដូចត្រីឆ្កិន) | Catla | *Catla catla* | ឥណ្ឌា នេប៉ាល់ បង់ក្លាដែស ប៉ាគីស្ថាន |
| ១១ | ត្រីអណ្តែងអាហ្វ្រិក | African Catfish | *Clarias gariepinus* | អាហ្វ្រិក និងអាស៊ីកណ្តាល |
| ១២ | (ដូចត្រីស) | Rohu | *Labeo rohita* | ឥណ្ឌា នេប៉ាល់ បង់ក្លាដែស ភូមា |
| ១៣ | អន្ទង់ | Japanese Eel | *Anguilla japonica* | ជប៉ុន កូរេ ចិន និងវៀតណាម |
| **គ) បង្កង** | | | | |
| ១ | (បង្កងជង្គៀបធំ) | Louisiana crayfish | *Procambarus clarkii* | សហរដ្ឋអាមេរិក |
| **ឃ) សត្វល្អិត** | | | | |
| ១ | កញ្ចៃដូង | Coconut leaf beetle | *Brontispa longissima* | ឥណ្ឌូនេស៊ី ប៉ាពូញ៉ូហ្គានៀ |
| ២ | ឃ្មុំអឺរ៉ុប | Euriopean Honeybee | *Apis mellifera* | ទ្វីបអាហ្វ្រិក |
| **ង) ល្មូន** | | | | |
| ១ | អណ្តើកត្រចៀកក្រហម | Red-eared Slider | *Trachemys scripta elegans* | សហរដ្ឋអាមេរិក |
| **ច) ខ្យង និងថលជលិក** | | | | |
| ១ | ខ្យងមាស | Apple Snail | *Pomacea gigas & Pomacea canaliculata* | ទ្វីបអាហ្វ្រិកខាងត្បូង |
| ២ | ខ្យងហ៊ាន | Giant african snail | *Achatina fulica* | ទ្វីបអាហ្វ្រិកខាងកើត |
| ៣ | កង្កែបក្បាលត្រួយចេក | North American Biullfrog | *Rana catesbiana* | ទ្វីបអាហ្វ្រិកប៉ែកឦសាន |

*******

នាយកដ្ឋានជីវៈចម្រុះ

# អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

# ក្រសួងបរិស្ថាន

ក្រោមជំនួយឧបត្ថម្ភពី (GEF/UNEP) តាមរយៈ

គម្រោង "បំបាត់ភាពរាំងស្ទះ ដល់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាតលើកិច្ចការពារ-អភិរក្ស និងផលិតកម្មព្រៃឈើ ក្នុងតំបន់អាស៊ីអាគ្នេយ៍-គម្រោង FORIS កម្ពុជា"